C6

# សួនដំណាំលក្ខណៈគ្រួសារ

## គោលការណ៍បច្ចេកទេស និង បទពិសោធន៍ជាក់ស្តែង



រៀបរៀងដោយ : មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក/CEDAC)

ខែ កុម្ភៈ ២០០៤

CEDAC

ACTION AGAINST HUNGER

VEGFAM

# អារម្ភកថា

សួនដំណាំជាលក្ខណៈគ្រួសារបានដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចគ្រួសារ ជាពិសេសកសិករក្រីក្ររស់នៅតាមជនបទ ដែលកំពុងជួបប្រទះនូវការលំបាក គ្រោះទុរភិក្ស ដោយសារទិន្នផលដំណាំទាប។ សំរាប់ជាជំនួយដល់កសិករ និងអ្នកបំរើការងារផ្សព្វផ្សាយ យើងបានចងក្រង សៀវភៅ សួនដំណាំជាលក្ខណៈគ្រួសារនេះ ដើម្បីផ្តល់ជាគំនិត ក្នុងការអនុវត្តន៏ផលិតកម្មកសិកម្ម ជាលក្ខណៈគ្រួសារអោយបានទិន្នផលខ្ពស់។

សៀវភៅនេះបានប្រមូលផ្តុំនូវចំណេះដឹង គំនិតសាមញ្ញៗ ស្តីពីការរៀបចំសួនដំណាំឱ្យបានល្អ ការកែលំអសួន ការគ្រប់គ្រង និងថែរក្សាដីជាតិដី។ល។ ព្រមទាំងបទពិសោធន៏ល្អៗ របស់កសិករក្នុងការដាំបន្លែ ដោយប្រើ ប្រាស់នូវប្រភពធនធានដែលមានស្រាប់នៅតាម ភូមិ ស្រុក ដែលគាត់រស់នៅ ។

សៀវភៅនេះរៀបចំចងក្រងដោយ **មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៏កសិកម្មកម្ពុជា (CEDAC)** សហការជាមួយ **អង្គការប្រឆាំងគ្រោះអត់ឃ្លាន (AAH)** ដោយមានការឧបត្ថម្ភថវិកាពីអង្គការ **Veg Farm** នៃចក្រភពអង់គ្លេស។

យើងខ្ញុំសង្ឃឹមថា សៀវភៅនេះអាចផ្តល់ជាគំនិត និងបទពិសោធន៏ដល់បងប្អូនកសិករក្នុងការបង្កើនផលិតផលដំណាំតាមគោលការណ៏ធម្មជាតិ និងដើម្បីជាទុនសំរាប់អ្នកស្រាវជ្រាវ និងផ្សព្វផ្សាយ។

យើងខ្ញុំសូមស្វាគមន៏នូវរាល់មតិយោបល់កែលំអផ្សេងៗ និងការចូលរួមចំណែកពីសំណាក់លោក លោកស្រី អ្នកនាងកញ្ញា ក្នុងការជួយឧបត្ថម្ភដល់ដំណើរការបោះពុម្ពផ្សាយបន្តទៀត។

**ក្រុមអ្នកនិពន្ធ**

# មាតិកា

អារម្ភកថា


១. សេចក្តីផ្តើម ........................................ ១

២. គោលការណ៍ និងគំនិតសំខាន់សំរាប់ជំនួយក្នុងការរៀបចំសួនដំណាំអោយបានល្អ ........................................ ២

២.១ ការគ្រប់គ្រង និងថែរក្សាជីជាតិដីឱ្យបានល្អ ........................................ ៣

២.២ ការជ្រើសរើស និងទុកដាក់ពូជ ........................................ ៥

២.៣ ការគ្រប់គ្រង និងប្រើប្រាស់ទឹកឱ្យបានល្អ ........................................ ៨

២.៤ ការជ្រើសរើសដំណាំសមស្របបានល្អ ........................................ ១០

២.៥ ការរៀបចំ និងអនុវត្តប្រព័ន្ធដាំដុះចំរុះបានល្អ ........................................ ១១

២.៦ ការគ្រប់គ្រង និងថែរក្សាកូនដំណាំ ........................................ ១៣

២.៧ ការប្រើប្រាស់ទឹកនៃ្លងដាំដុះបានល្អ ........................................ ១៥

២.៨ ការការពារដំណាំបានល្អ ........................................ ១៦

៣. គំនិតជ្រើសរើសសំខាន់ៗ សំរាប់យកទៅអនុវត្តក្នុងការកែលំអសួនដំណាំ ........................................ ១៩

៣.១ ជីកំប៉ុស្តទឹក ........................................ ១៩

៣.២ រងដំណាំដែលមានចង្អូរកណ្តាល ........................................ ២២

៣.៣ រងលើកខ្ពស់ ឬរងកាប់ជ្រៅ ........................................ ២៥

៣.៤ របៀបដាក់ជី និងស្រោចទឹកលើដំណាំឈើហូបផ្លែ ........................................ ២៩

៣.៥ សួនរង្វង់ ........................................ ៣១

៣.៦ ដំណាំជីស្រស់បៃតង ........................................ ៣៣

៣.៧ ការដាំបង្វិល ........................................ ៣៥

៣.៨ ថ្នាំសំលាប់សត្វល្អិតផ្សំពីរុក្ខជាតិ និងការធ្វើឱ្យសត្វល្អិតចង្រៃចាកចេញពីដំណាំ ........................................ ៣៧

៣.៩ ជីកំប៉ុស្ត ........................................ ៤០

៤. បទពិសោធន៍សំខាន់ៗ របស់កសិករក្នុងការដាំបន្លែ ........................................ ៤៤

៤.១ ការដាំល្ពៅឱ្យបានផ្លែច្រើន ........................................ ៤៤

៤.២ បទពិសោធន៍ក្នុងការដាំល្ពៅ ........................................ ៤៥

៤.៣ បទពិសោធន៍ដាំដំណាំត្រាវ ........................................ ៤៩

៤.៤ បទពិសោធន៍ដាំប៉េងប៉ោះ ..................................................... ៥២

៤.៥ បច្ចេកទេសដាំត្រប់របស់កសិករ **ឆុយ ឆុន** ........................................ ៥៦

៤.៦ បទពិសោធន៍ដាំផ្លែថាវ ..................................................... ៥៨

៤.៧ ននោង ១ គុម្ព ផ្តល់ផល ១៨០ ផ្លែ ..................................................... ៦០

៤.៨ របៀបទុកពូជប៉េងប៉ោះ ..................................................... ៦២

៤.៩ បច្ចេកទេសដាំខ្ទឹមស្លឹកលើរាន ..................................................... ៦៤

៤.១០ បទពិសោធន៍ដាំឃ្លោកនៅរដូវប្រាំង ..................................................... ៦៦

៤.១១ បទពិសោធន៍ដាំម្ទេសរបស់កសិករនៅស្រុកអង្គស្នួល ខេត្តកណ្តាល ..................................................... ៦៨

៤.១២ បទពិសោធន៍ដាំផ្ទីដូង ..................................................... ៧០

៤.១៣ បច្ចេកទេសដាំត្រឡាចឱ្យបានផ្លែច្រើន ..................................................... ៧៣

៤.១៤ បទពិសោធន៍ដាំចេកពងមាន់ ..................................................... ៧៦

## ១~ សេចក្តីផ្តើម

ជាទូទៅនៅជុំវិញផ្ទះ គ្រួសារកសិករតែងតែមានទីធ្លាដែលអាចប្រើប្រាស់សំរាប់ជាសួនដំណាំដែលក្នុងនោះមានដាំបន្លែ, ឈើហូបផ្លែ ក៏ដូចជាដាំដំណាំរួមផ្សំផ្សេងៗទៀត ។ សួនរបៀបនេះយើងហៅថាសួនគ្រួសារ ។

សួនគ្រួសារមានសារៈសំខាន់ណាស់សំរាប់គ្រួសារនីមួយៗ ។ តួនាទី និងសារៈសំខាន់របស់សួនដំណាំសំរាប់គ្រួសាររបស់អ្នកអាចមានដូចខាងក្រោមនេះ :

- ផ្តល់ស្បៀងអាហារ(បន្លែ-ផ្លែឈើ) សំបូរទៅដោយសារធាតុចិញ្ចឹមសំរាប់ ផ្គត់ផ្គង់តម្រូវការប្រចាំថ្ងៃរបស់គ្រួសារ
- ផ្តល់ចំណីសត្វ
- ផលិតផលលើស អាចលក់ដើម្បីបង្កើនប្រាក់ចំណូលក្នុងគ្រួសារ
- ផ្តល់នូវផលបន្ទាប់បន្សំផ្សេងទៀត ដូចជាផ្នែកផ្សេងៗនៃរុក្ខជាតិដែលអាចយកមកធ្វើជាថ្នាំបូរាណ និងផ្តល់ជាអុសសំរាប់ដុត ។
- ផ្តល់ការងារដល់សមាជិកគ្រួសារ
- ធ្វើឱ្យទិដ្ឋភាពជុំវិញផ្ទះមានភាពស្រស់បំព្រង ។



**ទិដ្ឋភាពរបស់សួនគ្រួសារ**

ដើម្បីឱ្យសួនដំណាំរបស់អ្នកបំពេញនូវតួនាទីខាងលើនេះបាន អ្នកត្រូវបង្កើតឱ្យមានសួនដ៏ល្អមួយ ។ ហើយសួនដែលល្អមានលក្ខណៈសំគាល់សំខាន់ៗដូចខាងក្រោមនេះ :

- អាចឱ្យអ្នកប្រមូលផលបានច្រើនប្រភេទ ជាពិសេសបន្លែនិងផ្លែឈើសំបូរដោយសារធាតុចិញ្ចឹមដល់រាងកាយ
- អាចឱ្យអ្នកប្រមូលផលបានគ្រប់រដូវទាំងប្រាំងទាំងវស្សា
- ដីមានជីជាតិល្អជានិច្ច ដោយមិនខ្សោះជីជាតិ និងបំពុលដោយសារធាតុគីមីទេ ។
- ជាកន្លែងប្រកបដោយផាសុខភាព គ្មានក្លិនជាតិពុល ដូចជា ថ្នាំ ពុល និងជីគីមី ។



**ភោគផលដំណាំដែលប្រមូលបានពីសួន**

តែសួនដែលល្អ វាមិនមែនកើតឡើងដោយឯកឯង ពោលគឺ ទាមទារឱ្យមានការគ្រប់គ្រង និងថែរក្សាឱ្យបានល្អ ។

ដើម្បីជំនួយដល់លោកអ្នកក្នុងការរៀបចំ និងគ្រប់គ្រងសួនដំណាំឱ្យបានល្អ ខ្ញុំសូមធ្វើការបង្ហាញពីគំនិត និងបទពិសោធន៍ខ្លះៗ ដែលមានរៀបរាប់ក្នុងកូនសៀវភៅនេះ ។

កូនសៀវភៅនេះមានចែកជា ៣ ផ្នែកសំខាន់ៗ ។ ផ្នែកទី ១ យើងធ្វើការណែនាំ*នូវគោលការណ៍និងគំនិតសំខាន់ៗ សំរាប់កែលំអសួនដំណាំ* ។ ចំណែកឯផ្នែកទី ២ វិញ មានការបង្ហាញពីបច្ចេកទេសសាមញ្ញៗ មួយចំនួនសំរាប់លោកអ្នកទៅសាកល្បង ។ នៅផ្នែកទី៣ យើងមានបង្ហាញនូវ*ឧទាហរណ៍ខ្លះៗ* របស់កសិករដែលអនុវត្តការដាំដុះ និងថែរក្សាដំណាំបន្លែ និងឈើហូបផ្លែបានល្អ ។

## ២. គោលការណ៍ និងគំនិតសំខាន់សំរាប់ជំនួយក្នុងការរៀបចំសួនដំណាំឱ្យបានល្អ

អ្នកគ្រប់គ្រងសួនបានល្អ ជាអ្នកមានលក្ខណៈពិសេសដូចខាងក្រោមនេះ :

១- មានការគ្រប់គ្រងថែរក្សាជីជាតិដីបានល្អ

២- ម្ចាស់សួនចេះ ជ្រើសរើស និងទុកដាក់ពូជបានល្អ

៣- មានការគ្រប់គ្រង និងប្រើប្រាស់ទឹកបានសមស្រប

៤- ម្ចាស់សួនចេះជ្រើសរើសប្រភេទដំណាំដាំបានសមស្របទៅតាមរដូវការដាំដុះនីមួយៗ

៥- ម្ចាស់សួនមានការរៀបចំ និងអនុវត្តប្រព័ន្ធដាំដុះបានល្អ

៦- មានការការពារដំណាំពីការបំផ្លាញផ្សេងៗបានល្អ

### ២.១. ការគ្រប់គ្រងថែរក្សាជីជាតិដីបានល្អ

សួនដែលមានដំណាំដុះលូតលាស់បានល្អដោយសារដីរបស់សួនមានជីជាតិល្អដែរ ។ ក្នុងសួនដំណាំ យើងអាចចាត់ទុក*ដីប្រៀបដូចជាម្តាយ ហើយដំណាំប្រៀបដូចជាទារក*។ បើម្តាយមានសុខភាពល្អ ទារកនោះក៏មានសុខភាពល្អដែរ ។ ដូចគ្នាដែរ បើដីមានសុខភាពឬមានជីជាតិល្អ ដំណាំក៏អាចលូតលាស់បានល្អដែរ ។

ចំពោះដីដែលល្អមានលក្ខណៈគេអាចសំគាល់បានដូចខាងក្រោមនេះ :

- ដីមិនគដ្ឋពេក មិនខ្សាច់ពេក
- ដីដែលមាន ឬសំបូរទៅដោយជាតិ*សរីរាង្គ*នៅស្រទាប់ ខាងលើ
- ដីដែលមានជំរៅជ្រៅ និងផុសល្អ ងាយស្រួលជីក
- ដីដែលមិនមានទឹកដក់ជាយូរ
- ដីដែលអាចចាប់ និងរក្សាសំណើម និងជីជាតិបានល្អ
- ដីដែលសំបូរដោយសត្វល្អិតរស់នៅ ដូចជាជន្លេន និងសត្វល្អិតមានប្រយោជន៍ផ្សេងៗទៀត
- ដីដែលមានក្លិនល្អ និងមានពណ៌ក្រម៉ៅ
- ដីដែលមានដំណាំច្រើនប្រភេទ (ជាពិសេសរុក្ខជាតិដុះឯង) ដុះលូតលាស់បានល្អ

ដើម្បីចង់ដឹងមើលតើដីយើងល្អប៉ុនណ្ណា យើងអាចចាប់ដីដែលសើមយកមកពូតមូលជាបាល់ ប្រសិនជាយើងមិនអាចមូលដូចជាបាល់បាន ពេលនោះមានន័យថា ដីយើងខ្សាច់ពេក ។ តែបើយើងពូត

មូលជាបាល់បាន ហើយផ្ទាត់មិនព្រមបែក មានន័យថាដីយើងឥដ្ឋពេកហើយ ។ ដីដែលមានទំរង់ល្អ គឺយើងអាចពូតមូលជាបាល់បាន ហើយនៅពេលផ្ទាត់វាអាចបំបែកជាដុំតូចៗបានបន្តិចម្តងៗ ។




**របៀបមើលលក្ខណៈរូបរបស់ដី**

ដើម្បីឱ្យបានដីល្អរបៀបនេះ គេច្រើនអនុវត្តនូវ បច្ចេកទេសខាងក្រោមនេះ :

- បើដីខ្សាច់ពេក គេបន្ថែមនូវដីឥដ្ឋ ឬដីដំបូកខ្លះៗ តែបើដី ឥដ្ឋពេក គេអាចបន្ថែមនូវដីខ្សាច់ខ្លះៗ
- បើដីជាំទឹកខ្លាំងគេត្រូវធ្វើ *ប្រព័ន្ធរំដោះទឹក* តាមរយៈការជីកជាកូនប្រឡាយ ឬចង្អូរនៅក្នុងសួន
- ប្រើប្រាស់ជីធម្មជាតិ ជាពិសេស *ជីកំប៉ុស្ត* (ជីដែលផ្សំពីជីធម្មជាតិផ្សេងៗ ហើយទុកឱ្យពុកល្អ) ដើម្បីឱ្យដីផុស និងអាចរក្សាសំណើមបានល្អ
- គេមិនដាំដំណាំមុខដដែលៗ លើដីដដែលទេ គឺគេផ្លាស់មុខ ដំណាំតាមរដូវ ( *ដំណាំបង្វិល* )
- គេដាំដំណាំ *ជីស្រស់បៃតង* ដើម្បីយកស្លឹកធ្វើជាជីដល់ដី
- គេ *គ្របដី* ជាប្រចាំដើម្បីការពារដីពីការរងនូវកំដៅថ្ងៃខ្លាំងដើម្បីរក្សាសំណើមក្នុងដីឱ្យបានល្អ និងការពារនូវការហូរសឹកនូវស្រទាប់ដីខាងលើ
- គេមិន *ប្រើជីគីមី និងថ្នាំពុល* ពីព្រោះវានាំឱ្យប៉ះពាល់ដល់ សត្វល្អិត ដែលរស់នៅក្នុងដី (ឧទាហរណ៍ជន្លេន)
- ការកាប់ *គាស់ដី ដោយមិនត្រឡប់នូវដីខាងលើ* មកក្រោម គឺគេគ្រាន់តែបំផុសដីតែប៉ុណ្ណោះ

ដើម្បីឱ្យដីរបស់សួនអ្នកមានជីជាតិល្អជាប់ជានិច្ច វាទាមទារឱ្យអ្នកអនុវត្តផ្គុំចូលគ្នានូវគោលការណ៍ និង គំនិតដូចខាងលើនេះចូលគ្នាឱ្យបានល្អ ។

## ២.២. ការជ្រើសរើស និងទុកដាក់ពូជបានល្អ

ពូជល្អជាកត្តាមួយចាំបាច់ណាស់ដើម្បីឱ្យដំណាំក្នុងសួនបានផលល្អ ។ កសិករដែលមានសួនល្អ តែងតែយកចិត្តទុកដាក់ណាស់ក្នុងការជ្រើសរើសនិងទុកដាក់ពូជ ហើយគេមិនចេះតែទិញ ឬយកគ្រាប់ពូជដែលមិនមានប្រភពច្បាស់លាស់មកដាំដែរ ។ ការមិនបានជ្រើសរើសពូជច្បាស់លាស់ វាអាចនាំមកនូវជម្ងឺរផ្សេងៗ ដោយពូជនោះមិនមានលក្ខណៈធន់ទៅនឹងល័ក្ខខ័ណ្ឌធម្មជាតិរបស់សួនយើង ឬពូជនោះវាមិនមានដំណុះល្អ ឬកំលាំងខ្សោយក្នុងការដុះ ឬពូជនោះនាំមកនូវជម្ងឺមកពីតំបន់ផ្សេងៗ ។

ដើម្បីធានាថា អ្នកបានពូជល្អមកដាំបន្ត គឺ *យើងត្រូវជ្រើសរើស និងទុកដាក់ពូជដោយខ្លួនឯង និងសហការជាមួយកសិករក្នុងភូមិ ដើម្បីចែករំលែកនិងដោះដូរពូជគ្នាទៅវិញទៅមក* ។

ដើម្បីជាជំនួយខ្លះៗដល់លោកអ្នកក្នុងការជ្រើសរើស និងទុកដាក់ពូជយើងខ្ញុំសូមផ្តល់នូវគំនិតមួយចំនួនដូចខាងក្រោមនេះ :

### ✍ របៀបផលិត និង ថែរក្សាគ្រាប់ពូជបន្លែ ដោយខ្លួនឯង

ក្នុងការដាំដុះ កសិករភាគច្រើនបានទិញគ្រាប់ពូជពីទីផ្សារមកដាំដែលមានតំលៃថ្លៃ ។ ក៏ប៉ុន្តែជួនកាល គ្រាប់ពូជទាំងនោះច្រើនមិនសូវមានគុណភាពល្អ ក៏រិតដុះទាប និងអាចនាំមកនូវជំងឺផ្សេងៗមកជាមួយផង ។ល។ អាស្រ័យដោយការទិញគ្រាប់ពូជដែលមានគុណភាពអន់នេះហើយដែលធ្វើឱ្យការដាំដុះទទួលបរាជ័យ ។ ដូច្នេះ ដើម្បីចៀសវាងនូវបញ្ហាខាងលើ បងប្អូនកសិករត្រូវចេះដាំ និងថែរក្សាគ្រាប់ពូជដោយខ្លួនឯង ។ ខាងក្រោមនេះជាយោបល់ណែនាំខ្លះៗ ដើម្បីជាជំនួយដល់បងប្អូនកសិករ ក្នុងការផលិតនិងទុកដាក់គ្រាប់ពូជដោយខ្លួនឯង :

**ដំណាក់កាលទី១** : ត្រូវពិនិត្យរកមើល តើដើម ឬ គុម្ពមួយណាដែលយើងជ្រើសរើសធ្វើពូជ ហើយ ដាក់សញ្ញាចំណាំដើម្បីចៀសវាងការច្រឡំ ឬប្រមូលផល ។

រីឯការជ្រើសរើស ត្រូវអនុវត្តតាមកត្តាខាងក្រោម :

- ☞ ជាដំបូងយើងត្រូវជ្រើសរើសដើមណាដែលមានសុខភាពល្អ ( គ្មានសត្វល្អិត និង ជំងឺបំផ្លាញ)
- ☞ ក្នុងចំណោមដើមដែលមានសុខភាពល្អ យើងត្រូវជ្រើសរើសដើមណាដែលឱ្យទិន្នផលល្អ ( ទំហំទ្រង់ទ្រាយ និងពណ៌ល្អ)



**ដំណាក់កាលទី២ :** ក្នុងចំណោមដើមដែលមានសុខភាពនិងឱ្យផលល្អ យើងត្រូវជ្រើសរើសផ្លែណាដែលមានរូបរាងល្អ ។ យកល្អចៀសវាងកុំបេះផ្លែទី១ គឺចាំបេះផ្លែទី២ ឬទី៣ ពីព្រោះយើងត្រូវចាំមើលសិន តើដើមនោះអាចផ្តល់ផ្លែល្អបានច្រើនឬទេ និងលូតលាស់បានល្អឬទេ ។ ជួនកាលដើមខ្លះមានតែ ផ្លែដំបូងល្អ តែផ្លែក្រោយៗសុទ្ធតែអន់ ឬដើមជួបនូវការបំផ្លាញផ្សេងៗ ។ នៅពេលផ្លែដែលយើងបានជ្រើសរើសនោះទុំល្អហើយត្រូវបេះទុក តែបេះនៅពេលដែលមេឃស្រឡះល្អ ចៀសវាងបេះនៅពេលមានភ្លៀង ។



**ដំណាក់កាលទី៣ :** ផ្លែដែលបេះបានត្រូវប្រឡេះយកគ្រាប់ហាលថ្ងៃឱ្យស្ងួតយ៉ាងឆាប់រហ័ស ។ គ្រាប់ខ្លះត្រូវលាងទឹកជាមុនសិន( ឧទាហរណ៍ ប៉េងប៉ោះ ល្ហុង ...។ល។) មុននឹងហាល ។ ការហាលនេះ គឺដើម្បីឱ្យគ្រាប់មានគុណភាពល្អគ្មានជំងឺ ។ ការហាលត្រូវហាលក្រោមពន្លឺព្រះអាទិត្យ នៅពេលព្រឹក រហូតដល់ថ្ងៃជិតត្រង់ ។ ការហាលចោលនៅពេលថ្ងៃត្រង់ និងថ្ងៃរសៀលមិនល្អទេ ពីព្រោះវាក្តៅពេក ហើយអាចបណ្តាលប៉ះពាល់ដល់ជីវិតរបស់គ្រាប់ ។ បទពិសោធន៍កន្លងមក គេច្រើនចំណាយពេលហាលពី ៣ ទៅ ៥ ម៉ោងនៅពេលព្រឹក ។ សូមបញ្ជាក់ផងដែរ ការហាលគឺធ្វើយ៉ាងណាឱ្យមានខ្យល់ចេញចូលបានល្អ ។

បន្ទាប់ពីបានហាលគ្រាប់ស្ងួតល្អមហើយ ត្រូវសំអាតឱ្យស្អាតដោយរើសគ្រាប់ខូចចោល យកតែគ្រាប់ល្អៗតែប៉ុណ្ណោះ ។



ហាលគ្រាប់ពូជ

**ដំណាក់កាលទី៤ :** ត្រូវយកគ្រាប់ពូជទុកដាក់នៅកន្លែងស្អាត ស្ងួត ងងឹត និងមានកំដៅទាប (ត្រជាក់) ។ ក្នុងការទុកដាក់គ្រាប់ពូជ ត្រូវរក្សាទុកក្នុងដប ឬប្រដាប់ច្រកដែលគ្មានខ្យល់ចូល ។ គ្រាប់ត្រូវរក្សាទុក ដោយលាយជាមួយសារធាតុមួយចំនួន ដែលអាចជួយស្រូបសំណើម និងជួយបណ្តេញខ្មូត ។ សារធាតុទាំងនោះមានដូចជា ផេះស្ងួត ធ្យូងស្ងួត ។

**ដំណាក់កាលទី៥ :** ប្រសិនបើយើងត្រូវការទុកគ្រាប់ពូជយូរ យកល្អយើងឧស្សាហ៍ចាក់គ្រាប់ពូជចេញ ដើម្បីយកមកហាល ហើយឧស្សាហ៍ប្តូរផេះ ឬធ្យូងដែលដាក់លាយជាមួយគ្រាប់ពូជ ។ រយៈពេលហាលម្តងៗ គឺមួយព្រឹកគ្រប់គ្រាន់ហើយ ។

**ដំណាក់កាលទី៦ :** ត្រូវបិទផ្លាកលើដប ឬកំប៉ុង ដើម្បីងាយស្រួលក្នុងការចំណាំទុក ។ អ្វីដែលគួរសរសេរ លើផ្លាកនោះមាន : ឈ្មោះដំណាំ ឬឈ្មោះពូជ ថ្ងៃ-ខែ-ឆ្នាំ នៃការប្រមូលផល កន្លែងដែលប្រមូលផល អ្នកដែលប្រមូលផល ។



ដូច្នេះ បងប្អូនកសិករគួរតែអនុវត្តនូវដំណាក់កាលទាំង ៦ ខាងលើឱ្យបានល្អ ដើម្បីថែរក្សាទុកគ្រាប់ពូជដោយខ្លួនឯងសំរាប់ដាំ នៅរដូវក្រោយទៀត ។

## ២.៣. ការគ្រប់គ្រង និង ប្រើប្រាស់ទឹកអោយបានល្អ

ទឹកជាធាតុមួយដ៏សំខាន់របស់រុក្ខជាតិ ដោយវាមាននៅគ្រប់ផ្នែកទាំងអស់របស់រុក្ខជាតិ ។ ទន្ទឹមនឹងនេះ ទឹកក៏មានតួនាទីជួយដឹកជញ្ជូននូវសារធាតុចិញ្ចឹមផ្គត់ផ្គង់ផ្នែកផ្សេងៗរបស់រុក្ខជាតិដែរ ។ ក្រៅពីនេះ ទឹកជាធាតុមួយសំខាន់ក្នុងការធ្វើ*រស្មីសំយោគ* មានន័យថា ក្នុងការផលិតនូវចំណីអាហារសំរាប់ចិញ្ចឹមឱ្យរុក្ខជាតិលូតលាស់ផ្លែផ្កាបានល្អ ។ បើគ្មានទឹករុក្ខជាតិក៏គ្មានជីវិត តែបើមានទឹកច្រើនពេក ក៏អាចឱ្យរុក្ខជាតិជាច្រើនមិនអាចលូតលាស់បានដែរ ។

គោលបំណងសំខាន់ក្នុងការគ្រប់គ្រងទឹកគឺ *លៃយ៉ាងណាកុំឱ្យដីស្ងួតពេក និងកុំឱ្យមានទឹកដក់ជាប់ ឬដីជាំទឹកខ្លាំងពេក* ។ មានន័យថា គេលៃយ៉ាងណាឱ្យមានសំណើមសមរម្យល្អសំរាប់ការលូតលាស់របស់ដំណាំ ។ គោលបំណងសំខាន់មួយទៀត គឺការប្រើប្រាស់ទឹកឱ្យមានប្រសិទ្ធិភាពក្នុងការស្រោចដំណាំ ជាពិសេសនៅរដូវរាំងស្ងួត ។

ចំណុចសំខាន់ដែលអ្នកត្រូវគិតគឺ បរិមាណទឹកដែលយើងត្រូវការស្រោចដំណាំ វាអាស្រ័យទៅលើ *ប្រភេទដំណាំ រដូវកាល* និង *លក្ខណៈធម្មជាតិរបស់ដី* :

ក- ប្រភេទដំណាំ : ជំរៅរបស់ឫស និងដំណាក់កាលលូតលាស់របស់ដំណាំ ។ ជាទូទៅ ដំណាំត្រូវការទឹកច្រើននៅពេលកំពុងលូតលាស់ មុនពេលចេញផ្កា និងពេលចេញផ្កា ។

ខ-បំរែបំរួលតាមរដូវកាលៈ កំដៅនិងពន្លឺ ល្បឿននៃខ្យល់ សំណើមនៃខ្យល់ និងបរិមាណទឹកភ្លៀង

គ- ធម្មជាតិរបស់ដី : សមត្ថភាពរបស់ដីក្នុងការស្រូប រក្សាសំណើម និងការបញ្ចេញសំណើមឱ្យដំណាំស្រូប។ ជាទូទៅដីដែលសំបូរទៅដោយសារធាតុសរីរាង្គ ឬជីធម្មជាតិអាចមានសមត្ថភាពខ្ពស់ក្នុងការស្រូបយក និងរក្សាសំណើម ។

គំនិតល្អដែលគេអាចយកទៅអនុវត្តជាពិសេសនៅរដូវប្រាំង មានដូចខាងក្រោមនេះ :

- *គ្របដី* ដើម្បីរក្សាសំណើម ជាពិសេសនៅរដូវក្តៅស្ងួត
- ប្រើ*ជីធម្មជាតិ* ដើម្បីបង្កើននូវ*សមត្ថភាពរក្សាសំណើមរបស់ដី*
- ធ្វើជា*សួនរង្វង់ ឬចង្អូរកណ្តាល* ដើម្បីងាយស្រួលក្នុងការស្រោចទឹក
- ស្រោច*របៀបជាដំណក់ៗ* ឬស្រោចទៅតាមស្រទាប់ដីខាងក្រោម ( ឧទាហរណ៍ ការបង្កប់ក្អម ឬទុយោ ដែលមានប្រហោងតូចៗ)
- ដាំដំណាំលៃទៅតាមបរិមាណទឹកដែលមាន

- ដាំដំណាំច្រើនជាន់ ឬដាំដំណាំកៀកៗគ្នា ដើម្បីងាយស្រោចទឹកតែមួយកន្លែង
- ប្រើប្រាស់នូវទឹកពីកាកសំណល់ផ្ទះបាយ
- ជ្រើសរើសដំណាំដែលធន់និងភាពរាំងស្ងួត
- យកទឹកទៅម្ជូតក្នុងសួន តែជៀសវាងកុំឱ្យទឹកសាប៊ូហូរចូល



**ការគ្របដីដើម្បីរក្សាសំណើម និងរក្សាដីជាតិដី**





ចំពោះក្នុងករណីរដូវវស្សា ជាពិសេសដើម្បីជៀសវាងកុំឱ្យមានភាពជាំទឹកខ្លាំង គេនាំគ្នាអនុវត្តនូវគំនិតសំខាន់ៗដូចខាងក្រោមនេះ :

- ធ្វើជាចង្អូរដើម្បីជួយរំដោះទឹកចេញកុំឱ្យដីជាំទឹកខ្លាំង ឬជីកជារណ្តៅតូចៗក្នុងសួន ហើយក្នុងរណ្តៅនេះ គេមានដាក់មែកឈើ ស្លឹកឈើ ដើម្បីឱ្យទឹកជ្រាបហូរចូលទៅក្នុងដី ។
- លើកជារងខ្ពស់ៗសំរាប់ដាំដំណាំ ឬធ្វើរងរបៀបជាធ្នើសំរាប់ដាំដំណាំ
- ដាំតែដំណាំណាដែលអាចលូតលាស់បានល្អ លើដីដែលជាំទឹក ឬដីងាយជាំទឹក

## ២.៤. ការជ្រើសរើសដំណាំសមស្របបានល្អ

នៅកម្ពុជាយើងមានដំណាំច្រើនប្រភេទណាស់ ដែលយើងអាចដាំបានតែការសំរេចចិត្តត្រូវដាំដំណាំអ្វីមួយលើកគ្នាជាច្រើន ។ ចំពោះកសិករដែលមានសួនល្អ គេតែងតែគិតគូរណាស់ក្នុងការជ្រើសរើសដំណាំ ។ ជាទូទៅគេជ្រើសរើសដំណាំដោយមានលក្ខណៈពិសេសដូចខាងក្រោមនេះ :

- *សមស្របទៅតាមរដូវកាល* ឧទាហរណ៍ រដូវប្រាំង គេដាំដំណាំដែលធន់នឹងភាពរាំងស្ងួត និង រដូវវស្សា គេដាំដំណាំដែលធន់នឹងភាពជាំទឹក
- *សមស្របទៅតាមជីជាតិដី* របស់សួន និងទីតាំងរបស់សួន ឧទាហរណ៍ ប្រសិនបើដីមិនសូវមានជីជាតិ គេជ្រើសរើសដំណាំណាដែលមិនសូវត្រូវការជីជាតិច្រើន
- *សមស្របទៅតាមតំរូវការរបស់គ្រួសារ* ជាពិសេសដំណាំ ដែលផ្តល់នូវសារធាតុចិញ្ចឹមច្រើន
- ភាពងាយ *ស្រួលក្នុងការផលិត និងទុកដាក់ពូជ*
- ដំណាំដែលអាចឱ្យ *ផលបានគ្រប់រដូវ*

ខាងក្រោមនេះជាដំណាំមួយចំនួនសំខាន់ដែលគេគួរជ្រើសរើសដាំសំរាប់សួនគ្រួសារ :

| | | |
|---|---|---|
| - ស្លឹកបាស | - គ្រប់គ្រប់ប្រភេទ | - ក្រូចឆ្មារ |
| - ជី | - ម្ទេស | - ចេក |
| - ត្រកួន | - ពពាយស្បែក | - ល្ហុង |
| - ជ្រលង់ | - សណ្តែកកួរ | - ឃ្លោក |
| - ស្លឹកគ្រៃ | - ម្រះ | - ដំឡូងជ្វា |
| - ជីគ្រប់ប្រភេទ | - ននោង | - ដំឡូងមី |
| - ខ្ទឹម | - ត្រឡាច | - ត្រាវ |
| - រំដេង | - ល្ពៅ | - ដំឡូងដៃខ្លា |
| - ល្មៀត | - ត្រសក់ | |

ទន្ទឹមនឹងនេះ គេក៏ដាំរុក្ខជាតិឈើមួយចំនួនទៀតដែរ ដូចជា រលោះ ម្រុំ ស្ដៅ កន្ទំថេត អង្គារដី ។ល។ ដែលគេអាចយកមកប្រើជាបន្លែបានដែរ ។ ចំពោះរុក្ខជាតិមួយចំនួន ដូចជាកន្ទំថេត រលោះ អង្គារដី វាទាមទារឱ្យ មានការកាប់មែកឱ្យបានទៀងទាត់ ដើម្បីគេអាចបេះស្លឹកធ្វើជាបន្លែបាន ។

## ២.៥. ការរៀបចំ និងអនុវត្តប្រព័ន្ធដាំដុះចំរុះដាំចម្រុះ

ការអនុវត្តន៍នូវប្រព័ន្ធចំរុះ( ដាំដំណាំច្រើនមុខលើដីសួន) ផ្តល់ផលប្រយោជន៍ដល់ការការពារដំណាំ ពីព្រោះវានាំមកនូវភាពចំរុះនៃសត្វរស់នៅក្នុងសួន និងតុល្យភាពរវាងសត្វមានប្រយោជន៍ និងសត្វដែលបំផ្លាញដំណាំ ។

ទន្ទឹមនឹងនេះ ការដាំដំណាំច្រើនមុខ ក៏អាចជួយដល់ជីជាតិដីដែរ ដោយដំណាំនីមួយៗត្រូវការ និងស្រូបយកជីជាតិពីដីមានខុសៗគ្នា។ ផ្ទុយទៅវិញ ការដាំដំណាំតែមួយមុខគត់នៅលើដីតែមួយបង្ករលក្ខណៈងាយស្រួលឱ្យសត្វល្អិតដែលបំផ្លាញដំណាំក្នុងការប្រមូលផ្តុំ និងធ្វើការស្រូបជីជាតិដីដដែលៗអស់ចេញពីដី។



**របៀបដាំចំណាំចំរុះនៅលើរងតែមួយ**

ប្រព័ន្ធដាំដុះចំរុះដែលគេអាចអនុវត្តបានក្នុងសួនដំណាំមានដូចជា :

- ការដាំដំណាំច្រើនមុខលាយគ្នាលើដីតែមួយ
- ការដាំដំណាំឆ្លាស់តាមរង ( ឧទាហរណ៍ រងមួយមានដាំសណ្តែកកួរ ហើយរងមួយទៀតមានដាំត្រប់)
- ការដាំបង្វិលមុខដំណាំទៅតាមរដូវ ( ឧទាហរណ៍ នៅកន្លែងមួយមានដាំសណ្តែកកួរ តែរដូវក្រោយត្រូវដាំនូវម្ទេស ឬដំណាំផ្សេងទៀតដែលខុសពីពួកសណ្តែក)
- ការដាំច្រើនជាន់ ( ការមានដាំដំណាំវារឡើងទ្រើង ហើយនៅខាងក្រោមទ្រើង មានដាំដំណាំ

ផ្សេងទៀត ជាពិសេសដំណាំដែលធន់នឹងម្លប់)

- ការបញ្ចូលនូវដើមឈើក្នុងប្រព័ន្ធដាំដុះ (ដើមឈើសំខាន់មានដូចជា អង្គារដី ដែលគេអាចដាំនៅក្នុងសួនបានដោយវាមិនសូវមានម្លប់ខ្លាំង អាចជួយស្រូបជីជាតិមកចិញ្ចឹមដំណាំដទៃទៀត)

ក្រៅពីរបៀបដាំដូចមានរៀបរាប់ខាងលើនេះ គេអាចដាំតាមរបងនូវដើមឈើមួយចំនួនដូចជា រលោះ កន្ទំធេត ស្ដៅ ជាដើមឈើដែលគេអាចប្រើប្រាស់ជាអាហារបានដែរ ។



**របៀបដាំច្រើនជាន់**

## ២.៦. ការគ្រប់គ្រង ថែរក្សាកូនចំណាំ

ការដាំដំណាំមានច្រើនរបៀប ដូចជាការដាំដោយគ្រាប់ផ្ទាល់ ការដាំដោយប្រើមែក ទង ដើម និង មើម និងការដាំដោយបណ្តុះគ្រាប់ ហើយបានដកកូនទៅដាំឬទៅស្ទូង ។ ដំណាំបន្លែជាច្រើនប្រភេទ ត្រូវបានគេអនុវត្តការដាំរបៀបបណ្តុះកូនជាមុនសិនមុនដាំ ដោយគេយល់ថាវាអាចមានលក្ខណៈប្រសើរជាងការដាំដោយគ្រាប់ ផ្ទាល់ ( ឧទា. ម្ទេស, ត្រប់, ប៉េងប៉ោះ) ។

ក្នុងករណីគេបណ្តុះគ្រាប់ ហើយបានដកកូនយកទៅដាំ គោលបំណងសំខាន់១គឺគេចង់បានកូនដំណាំដែលមានសុខភាពល្អ កម្លាំងខ្លាំងយកទៅដាំ ហើយលៃយ៉ាងណាបន្ទាប់ពីដាំហើយ កូនដំណាំនោះអាចមានលទ្ធភាពលូតលាស់បានល្អភ្លាម ។



**ថ្នាលបណ្តុះកូនចំណាំ**

គំនិតសំខាន់១ ដែលយើងអាចជ្រើសរើសសំរាប់យកទៅអនុវត្តមាន :

- យកតែ *គ្រាប់ថ្លោស* ពេញល្អទៅសាប
- *សាបស្តើងល្មម* ដើម្បីឱ្យកូនដំណាំអាចរីកមាឌបានល្អ
- ប្រើ *ជីកំប៉ុស្ត* រោយលើផ្ទៃខាងលើរបស់ថ្នាលមុននឹងសាប
- ថែរក្សាថ្នាលឱ្យបានល្អ ជាពិសេសការពារកុំឱ្យមានទឹកដក់ ដាំខ្លាំងឈ្នាំងស្ងួតខ្លាំង ក៏ដូចជាទទួលបំផ្លាញសត្វល្អិត និងជម្ងឺ
- ដកតែ *ដើមថ្លោស* ទៅដាំ

- ពេលដក ការពារកុំឱ្យមានការប៉ះពាល់ខ្លាំងដល់ឫស *ដោយដកថ្នមៗ* ហើយមានដោយដីជាប់ទៅជាមួយខ្លះៗ និងការពារកុំឱ្យឫសកូនដំណាំប៉ះពន្លឺថ្ងៃខ្លាំងពេលដកទៅដាំ
- ដកកូនភ្លាមយកទៅដាំ ឬស្ទូងភ្លាមកុំទុកយូរចាំឱ្យស្រពោនអន់ដើម
- ដាំដោយថ្នមៗហើយកុំកប់ឫសកូនដំណាំជ្រៅពេក
- យកល្អដាំនៅពេលថ្ងៃល្ងាច ដើម្បីកុំឱ្យដំណាំរងនូវពន្លឺថ្ងៃខ្លាំងពេក
- ដាំហើយយកល្អគ្របគល់ដើម្បីរក្សាសំណើមឱ្យបានល្អ




ការដាស់កូនដំណាំយកទៅដាំ ដោយមានការប្រុងប្រយ័ត្នបំផុត



ចំណុចសំខាន់ដែលអ្នកត្រូវរងចាំពេលដកកូនដំណាំទៅដាំ គឺកូនដំណាំទាមទារឱ្យមានការថ្នាក់ថ្នម ប្រៀប ដូចក្មេង តូច ឬ កូនង៉ែត ។

## ២.៧. ការប្រើប្រាស់ទីកន្លែងដាំដុះអោយបានល្អ

ស្ថានភាពដីរបស់សួនអាចមានលក្ខណៈខុសៗគ្នាដោយអាស្រ័យទៅលើភាពខ្ពស់ទាប ភាពជិត ឬឆ្ងាយពីទឹក ភាពនៅជិតឬឆ្ងាយពីផ្ទះ ភាពទទួលម្លប់ឬទទួលពន្លឺថ្ងៃពេញលេញ ។ ដូចនេះនៅពេលរៀបចំបួងដាំដុះ យើងត្រូវគិតគូរអំពីបញ្ហាទាំងនេះ ។

- កន្លែងដែលមានម្លប់ច្រើន យើងត្រូវដាំដំណាំដែលធន់នឹងម្លប់
- កន្លែងដែលដីរាងទាប ហើយងាយដក់ទឹក យើងត្រូវដាំដំណាំដែលសមស្របទៅនឹងស្ថានភាពរបៀបនេះ
- កន្លែងដែលនៅជិតទឹក យើងគួរដាំដំណាំដែលត្រូវការទឹកច្រើន ឬទាមទារការស្រោចទឹកញឹកញាប់
- នៅជិតផ្ទះ យើងដាំដំណាំដែលត្រូវការថែទាំញឹកញាប់ និងត្រូវការជាប្រចាំថ្ងៃ

## ២.៤. ការការពារដំណាំបានល្អ

ក្រៅពីនេះ គេក៏គួរប្រើទីធ្លាដែលមាន ឱ្យមានប្រសិទ្ធិភាពតាមរយៈការអនុវត្តនូវការដាំដុះតាមរបៀបច្រើនជាន់ និងការដាំតាមរបង ឬការដាំធ្វើជារបងរស់ ។

ជាទូទៅដំណាំរបស់យើង តែងតែមានជួបបញ្ហានូវការបំផ្លាញពីសត្វល្អិត និងជម្ងឺផ្សេងៗ( បង្ករដោយមេរោគ ដូចជាផ្សិត បាក់តេរី ។ល។) គ្រាន់តែកំរិតនៃការបំផ្លាញវាមានកំរិតខុសៗគ្នា ។ ក្រៅពីសត្វល្អិតនិងជំងឺ ក៏អាចជួបបញ្ហាបំផ្លាញដោយសារតែមកពីការខ្វះជីជាតិដី ឬសារធាតុចិញ្ចឹម ឬ អាចដីជាំទឹកពេក ។

ចំពោះអ្នកគ្រប់គ្រងសួនដំណាំតាមគោលការណ៍ធម្មជាតិ គេយល់ថាបញ្ហារបៀបនេះវាតែងតែមាននៅក្នុងធម្មជាតិ ។ ដើម្បីជៀសវាងកុំឱ្យមានបញ្ហានេះកើតមានឡើងធ្ងន់ធ្ងរ គេតែងតែអនុវត្តតាមគោលការណ៍ការពារប្រសើរជាងព្យាបាល ។ តែបើបញ្ហានៅតែកើតមានឡើង គេអនុវត្តនូវវិធានការសមស្របមួយ ក៏គេចុះចាញ់ដោយសមរម្យ ។



**សត្វមានប្រយោជន៍អាចជួយការពារដំណាំរបស់អ្នក**

អ្នកការពារដំណាំដោយអនុវត្តតាមគោលការណ៍ធម្មជាតិ គេយល់ឃើញថា ជាទូទៅប្រសិនបើយើងម្នាក់ៗ អនុវត្តនូវវិធានការខាងក្រោមនេះបានច្បាស់ជាបញ្ហាទាក់ទងទៅនឹងសត្វល្អិត និងជម្ងឺមិនអាចកើតមានធ្ងន់ធ្ងរទេ :

- ការយកចិត្តទុកដាក់លើការកែលំអរ ថែរក្សាជីជាតិដី
- ការជ្រើសរើស និងទុកដាក់ពូជឱ្យបានល្អ

- ការធានាឱ្យដំណាំមានការចាប់ផ្ដើមបានល្អនៅក្នុងសួន( ការគ្រប់គ្រងនិងថែរក្សាកូនដំណាំឱ្យបានល្អ)
- ការជ្រើសរើសដំណាំឱ្យសមស្របទៅនឹងរដូវកាល និងទីកន្លែង
- ការពារកុំឱ្យសត្វល្អិតមកស៊ីដំណាំតាមរយៈការចុះពិនិត្យសួន ដោយយកចិត្តទុកដាក់
- ការដកស្មៅបំផុសដីបានល្អ
- ការអនុវត្តនូវប្រព័ន្ធដាំដុះចំរុះ
- មានការបង្ហូរទឹកបានល្អ ជៀសវាងកុំឱ្យដីមានភាពជាំទឹក
- ស្គាល់នរណាជាមិត្ត នរណាជាសត្រូវធម្មជាតិរបស់ដំណាំ ហើយការពារនិងបង្ករល័ក្ខខ័ណ្ឌឱ្យមិត្តរបស់ដំណាំអាចរស់នៅបានល្អ តាមរយៈការមិនប្រើថ្នាំពុល ការបង្កើតនូវជម្រកផ្សេងៗ ការមិនចាប់សម្លាប់សត្វទាំងនោះ ( ឧទាហរណ៍ កង្កែប, តឹង្កក់ ។ល។ )
- ដាំដំណាំបណ្ដេញសត្វល្អិតចង្រៃ ( ដំណាំដែលមានក្លិនក្រពុលដូចជា ជី ស្លឹកគ្រៃ ផ្កាស្បៃរឿង ។ល។

តែប្រសិនបើ សួនដំណាំជួបបញ្ហាបំផ្លាញដោយសត្វល្អិត និងជម្ងឺផ្សេងៗ គេតែងតែអនុវត្តដូចខាងក្រោមនេះ :

- កំណត់ពីបញ្ហាឱ្យបានច្បាស់លាស់
- ស្វែងយល់ពីមូលហេតុឱ្យបានច្បាស់
- ប្រមូលនូវដំណោះស្រាយ ឬជំរើសផ្សេងៗ
- សំរេចចិត្តអនុវត្តនូវជំរើសណាមួយដែលសមស្រប( ឧទាហរណ៍ ការប្រើថ្នាំដែលផ្សំពីរុក្ខជាតិ)
- ធ្វើការវាយតម្លៃនូវលទ្ធផលនៃការអនុវត្ត
- បើទៅមិនរួច ចុះចាញ់ប្រកបដោយសន្តិភាព

ជាទូទៅគេតែងតែពិភាក្សាជាមួយអ្នកជិតខាង និងអ្នកមានបទពិសោធន៍ច្រើន ដើម្បីស្វែងយល់ពីបញ្ហាឱ្យបានច្បាស់លាស់ ហើយប្រមូលនូវបទពិសោធន៍ ឬដំណោះស្រាយផ្សេងៗ ។ គេមិនឈានទៅរកការអនុវត្តរបៀបរហ័សតាមរយៈការប្រើថ្នាំពុលទេ ជាពិសេសថ្នាំពុលគីមី ។ ការប្រើថ្នាំពុលគីមីគ្រាន់តែជាដំណោះស្រាយខ្លីទេ ហើយវានាំមកនូវបញ្ហាជាច្រើន រហូតអាចឈានទៅដល់គ្រោះថ្នាក់ដល់អាយុជីវិតអ្នកប្រើថ្នាំផង ។ ប្រសិនបើករណីចាំបាច់ គួរប្រើ*ថ្នាំផ្សំពីរុក្ខជាតិ* ដើម្បីបណ្ដេញ និងសម្លាប់សត្វដែល

បំផ្លាញដំណាំ ។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏ថ្នាំផ្សំពីរុក្ខជាតិ ក៏មានគ្រោះថ្នាក់ដែរ ហើយវាទាមទារឱ្យមានការប្រើប្រាស់ប្រកបដោយការប្រុងប្រយ័ត្នជានិច្ច ។




**ការប្រើថ្នាំពុលកសិកម្មអាចនាំមកនូវបញ្ហាជាច្រើន**
**ប្រភេទរបស់អ្នក និងគ្រួសាររបស់អ្នក**

**“ សុខភាពរបស់អ្នកវាប្រសើរជាងប្រាក់ចំណេញរាប់លានរៀល ”**

## ៣_ គំនិតជ្រើសរើសសំខាន់ៗសំរាប់យកទៅអនុវត្តក្នុងការកែលំអរស្ទួនដំណាំ

### ៣.១. ជីកំប៉ុស្តទឹក

#### ១_ អ្វីទៅជាកំប៉ុស្តទឹក ?

ជីកំប៉ុស្តទឹក ជាជីរាវដែលបានមកពីតាមរយៈការត្រាំសារធាតុសរីរាង្គ ជាពិសេសលាមកសត្វមាន់ ទា និង ស្លឹកឈើផ្សេងៗ។

#### ២_ ហេតុអ្វីបានជាចាំបាច់ធ្វើ និងប្រើជីទឹកនេះ?

ជីទឹក ប្រសិនបើយើងធ្វើឱ្យបានស្រួលបួល វាសំបូរទៅដោយ *មីក្រូសរីរាង្គ* (សត្វតូចៗ ដែលមិនអាចមើលនឹងភ្នែកបាន) ដែលមានសារៈប្រយោជន៍ដល់ជីជាតិរបស់ដី ។ ទន្ទឹមនឹងនេះ ជីទឹកក៏មានទ្ធូវសារធាតុចិញ្ចឹម(ជី) ដែលរលាយរួចស្រេច សំរាប់ងាយស្រួលដល់ដំណាំស្រូបយក ។ ប្រសិនបើយើងត្រាំរុក្ខជាតិដែលមានក្លិនខ្លាំង ជីនេះ ក៏អាចជួយដេញសត្វល្អិតដែលបំផ្លាញរុក្ខជាតិកុំឱ្យមកជិតដែរ ។

#### ៣_ តើវត្ថុដើមអ្វីខ្លះដែលសមស្របសំរាប់ធ្វើជីទឹក?

សារធាតុសំខាន់ៗ ដែលប្រើសំរាប់ធ្វើជីទឹក មានលាមកសត្វមាន់ ទា ប្រចៀវ ស្លឹករុក្ខជាតិដែលមានឫសជ្រៅៗ ជាពិសេសរុក្ខជាតិដុះឯង ហើយមានក្លិនខ្លាំង ដូចជា *ទន្ទ្រានខែត្រ កន្ទ្រោបព្រៃ* ។ល។ ចំពោះស្លឹកពពួកកួរ ឧទាហរណ៍: *ស្លឹកអង្កាញ់, កន្ទំថេត, អង្គាដី* ក៏អាចយកមកប្រើធ្វើជាទឹកបានល្អដែរ ដោយវាសំបូរទៅដោយសារធាតុអាសូត ។


ស្លឹកទន្ទ្រានខែត្រ


ស្លឹកអង្គាដី


ស្លឹកកន្ទ្រោបព្រៃ


លាមកមាន់ ទាប្រចៀវ

## ៤. តើគេធ្វើជីទឹកយ៉ាងដូចម្ដេច?

ក- សំភារៈ

- គេត្រូវការពាងមួយ ( អាចជាកូនពាងស្ករ ពាងទឹក ឬធុងសាំង)
- គេត្រូវការបាវធ្វើពីក្រចៅមួយសំរាប់ច្រក
- ដុំថ្មមួយដុំសំរាប់សង្កត់ឱ្យបាវលិច

ខ- របៀបធ្វើ

- ច្រកវត្ថុធាតុដើម ( ស្លឹកឈើ លាមកសត្វ) ចូលក្នុងបាវ ដោយវាស់បរិមាណឱ្យបានច្បាស់លាស់
- ដាក់បាវដែលច្រកជីហើយចូលក្នុងពាង រួចដាក់ដុំថ្មសង្កត់ពីលើ
- ចាក់ទឹកចូលក្នុងពាង ដោយចំណុះទឹកស្មើនឹង ២០ ដង នៃចំណុះជី ( ឧទាហរណ៍ ប្រសិនបើយើងច្រកជីមួយប៉ោតចូលក្នុងបាវ យើងត្រូវចាក់ទឹក ២០ ប៉ោតចូលក្នុងពាង)
- បិទពាង ដោយប្រើគំរបធ្វើពីឈើ

គ- របៀបថែរក្សា

- យើងត្រូវគ្របពាងជីឱ្យបានល្អ ដើម្បីការពារកុំឱ្យរុយមកពងដាក់ និងជះក្លិនស្អុយចេញមកខាងក្រៅ
- ដាច់ខាតត្រូវកូរជីរៀងរាល់ថ្ងៃ ដោយមួយថ្ងៃត្រូវកូរ ២ ដង ។




នៅពេលកូរម្ដងៗយើងត្រូវកូរឱ្យបានប្រហែល៥ នាទី ហើយរបៀបកូរគឺកូរបង្វិលទៅបង្វិលមក។ ការកូរមានសារៈសំខាន់ណាស់ ពីព្រោះវានាំខ្យល់ ( អុកស៊ីសែន) ចូលក្នុងទឹក ហើយបង្កល័ក្ខខ័ណ្ឌឱ្យពួកសត្វល្អិតតូចៗ ដែលរស់នៅត្រូវការអុកស៊ីសែនមានសកម្មភាពខ្លាំង ។ ផ្ទុយទៅវិញ បើយើងមិនកូរ នោះជីរបស់យើងនឹងសំបូរទៅដោយ *ពពួកមេរោគ ដែលមិនត្រូវការខ្យល់* ។

## ៥. តើគេប្រើជីទឹកយ៉ាងដូចម្តេច ?

៣ អាទិត្យក្រោយមក យើងដួសទឹកជីយកទៅប្រើបាន ។ យើងអាចដឹងថាជីរួចរាល់សំរាប់ប្រើបាននៅពេលដែលវាលែងមានក្លិនស្អុយ ។ ជីដែលរួចរាល់អាចរក្សាទុកបានប្រហែលរយៈពេលមួយខែទៀត តែត្រូវទុកវាក្រោមម្លប់ ។ នៅពេលជីដែលរួចរាល់ហើយសំរាប់ប្រើ *យើងចៀសវាងកុំបោះវត្ថុធាតុដើមចូលបន្ថែមទៀត គឺប្រើឱ្យអស់សិន រួចចាំធ្វើថ្មីតែម្តង* ។

*របៀបស្រោច*

- គេស្រោចជីទឹក ១ លីត្រ លើផ្ទៃដី ១ ម៉ែត្រការ៉េ (១ ម៉ែត្របួនជ្រុង) តែបើស្រោចលើស្លឹកដំណាំផ្ទាល់ គេត្រូវលាយជីជាមួយទឹកធម្មតាមួយទល់មួយ ។ យើងគួរស្រោចមួយសប្តាហ៍ម្តងតែបើដំណាំជួបបញ្ហាខ្វះជីជាតិ ខ្លាំង យើងអាចស្រោចពី ២ ទៅ ៣ ដង ក្នុងមួយសប្តាហ៍ ។

*ដំណាក់កាលសំខាន់ៗ សំរាប់ប្រើជីទឹកមាន*

- ពេលកូនដំណាំកំពុងលូតលាស់
- មុនពេលចេញផ្កា
- ពេលដំណាំជួបរោគសញ្ញាប្លែក ឧទាហរណ៍ស្លឹកមានការប្តូរពណ៌ ឬដំណាំបង្ហាញនូវរោគខ្វះជីជាតិ

## ៦. តើការប្រើជីទឹកមានគុណសម្បត្តិ និងគុណវិបត្តិយ៉ាងណាខ្លះ?

*គុណសម្បត្តិ*

- ងាយធ្វើ ធនធានតិច
- ឆាប់បានប្រើ ហើយបានលទ្ធផលលឿន
- ផ្តល់ជីជាតិច្រើនមុខ និងធ្វើឱ្យដីមានជីជាតិ
- ជួយការពារដំណាំបានខ្លះៗ

*គុណវិបត្តិ*

- មានក្លិនមិនសូវល្អ ជាពិសេស ពេលត្រាំដំបូង
- ទាមទារឱ្យកូររាល់ថ្ងៃ
- បើមិនបានកូរទៀងទាត់ នាំឱ្យមានមេរោគកើតឡើង
- ត្រូវធ្វើ ២ ទៅ ៣ ពាង ប្រសិនបើចង់ប្រើច្រើន ឬប្រើតជាប់ៗគ្នា ។

## ៣.២. រងដំណាំដែលមានចង្អូរកណ្ដាល

រងដំណាំដែលមានចង្អូរកណ្ដាលជារង ដែលគេជីកកូនរណ្ដៅវែងតូចមួយនៅចំកណ្ដាល និងបណ្ដោយទៅតាមផ្ទៃរង ។ គេប្រើកូនចង្អូរតូចនេះសំរាប់ដាក់ជីធម្មជាតិ និងស្រោចទឹក ។ ពេលដំណាំលូតលាស់ ឫសរបស់វាប្រមូលផ្ដុំនៅកន្លែងដាក់ជី និងស្រោចទឹកនោះ ។ ការធ្វើរបៀបនេះងាយស្រួលដល់យើងក្នុងការឱ្យជី និងទឹកចំមាត់ដំណាំតែម្ដង (ពីព្រោះឫសដែលលូតលាស់មកថ្មីៗ ជាឫសដែលស្រូបទឹក និងជី) ។

<u>របៀបធ្វើរងដាំ និងថែទាំ</u> :

១- យើងលើកដីធ្វើជារងតាមរបៀបធម្មតា ដោយទទឹងរបស់រង អាចមានប្រវែងប្រហែល ១ ម៉ែត្រ ។



**រងធម្មតា**

២- បន្ទាប់ពីលើករងហើយ យើងយកចបមកជីកជាចង្អូរចំកណ្ដាល ដោយទទឹងរបស់ចង្អូរមានប្រវែងប្រហែល ៣ តឹក និង ជំរៅប្រហែល ៣ តឹកដែរ ។



**ការជីកចង្អូរកណ្ដាលរង**

៣- ពេលជីកចង្អូរហើយយើងរៀបដីនៅសងខាងឱ្យបានស្មើល្អ ។ បន្ទាប់មកប្រមូលជីធម្មជាតិផ្សេងៗ យកមកដាក់ចង្អូរ (ដែលមានជីលាមកសត្វសុទ្ធ) លាយជាមួយស្លឹកឈើសុទ្ធ និងកាកសំណល់រុក្ខជាតិផ្សេងៗ (ចៀសវាងការប្រើជីលាមកសត្វសុទ្ធ) ។ បើយើងមានជីកំប៉ុស្ត យើងគួរលាយជាមួយដែរ ។



**ការដាក់ជីធម្មជាតិក្នុងចង្អូររង**

៤- បន្ទាប់មក យើងអាចយកកូនដំណាំមកដាំ ឬកប់គ្រាប់ដំណាំ ។ ដំណាំដែលសមស្របសំរាប់រងរបៀបនេះច្រើនពពួកដែលមានឫសវែងល្មម ដូចជា សណ្តែកកួរ ត្រប់ ត្រសក់ ម្រះ ម្ទេស ប៉េងប៉ោះ ។ល។



**ការដាំដំណាំលើរង**

៥- នៅពេលដំណាំដុះលូតលាស់ល្អហើយ យើងមិនបាច់ស្រោចទឹកចំគល់របស់វាទេ គឺយើងគួរស្រោចតែតាមចង្អូរបាន ហើយឫសនឹងប្រមូលផ្ដុំនៅក្នុងចង្អូរនោះ។ នៅពេលដំណាំកំពុងលូតលាស់ ដីនៅកណ្ដាលចង្អូរត្រូវរលួយហើយស្រុតចុះក្រោម។ ដូចនេះ យើងគួរខុស្សាបន្ថែមដី តែចៀសវាងប្រើលាមកសត្វស្រស់ ។



**ការស្រោចដំណាំ**

៦- ក្នុងករណីពពួកដំណាំឡើងទ្រើងយើងអាចដាក់ទ្រើងឱ្យវារឡើងធម្មតា តែត្រូវទុកចន្លោះសំរាប់ស្រោចទឹកផង ។



**ការដាក់ទ្រើងឱ្យដំណាំវារឡើង**

បើចង់ដឹងថារងរបៀបនេះមានផលប្រយោជន៍យ៉ាងណា សូមបងប្អូនធ្វើការសាកល្បងចំនួន ២ ទៅ ៣ រងមើលសិន ។

## ៣.៣. រងលើកខ្ពស់ ឬរងកាប់ជ្រៅ

រងលើកខ្ពស់ ឬរងកាប់ជ្រៅ ជាប្រភេទរងមួយមានជារណ្ដៅ ឬពំនូនដែលក្នុងរណ្ដៅ ឬពំនូននេះ គេកប់បញ្ចូលនូវសារធាតុសរីរាង្គ ជាពិសេសរុក្ខជាតិផ្សេងៗ ។ រងនេះមានលក្ខណៈសមស្របបំផុតចំពោះ តំបន់ណាដែលដីមិនសូវផុសល្អ ឬមានការជាំទឹកខ្លាំង ។ ការធ្វើរបៀបនេះ ផ្ដល់នូវផលប្រយោជន៍យ៉ាង ច្រើនដល់ម្ចាស់សួន :

- ☞ រុក្ខជាតិអាចចាក់ឫសបានស្រួលដោយសារដីផុសល្អ
- ☞ រក្សាសំណើមក្នុងដីបានយូរ ហើយមិនសូវទាមទារឱ្យមានការស្រោចទឹកញឹកញាប់ (ជាពិសេសនៅពេលឫសចាក់ដល់ស្រទាប់ដីដែលរលួយ)
- ☞ ផ្ដល់ជីជាតិបន្តិចម្ដងៗ តាមរយៈភាពពុកនៃសារធាតុសរីរាង្គដែលមានក្នុងរណ្ដៅ ឬពំនូន
- ☞ ទប់ស្កាត់ការហូរសឹក ឬហូរច្រោះដោយទឹកជ្រាបចូលក្នុងដីបានលឿន
- ☞ អាចដាំដំណាំបន្លែបានមួយសារទៀត ក្រោយពីប្រមូលផល ដោយមិនទាមទារឱ្យលើករងថ្មី គឺគ្រាន់តែជ្រោយដីប៉ុណ្ណោះ ។ ក៏ប៉ុន្តែ គេត្រូវដូរប្រភេទដំណាំ ។

ទន្ទឹមនឹងគុណសម្បត្តិ រងខ្ពស់ក៏អាចនាំបញ្ហាមួយចំនួនដែរ ដូចជា :

- ☞ ត្រូវការសារធាតុសរីរាង្គច្រើន
- ☞ ត្រូវការកំលាំងច្រើនជាងការធ្វើរងធម្មតា
- ☞ ពេលដំបូង ការលូតលាស់របស់បន្លែរាងយឺត ដោយសារធាតុសរីរាង្គ មិនទាន់ពុកផុយ ។

*របៀបធ្វើ និង ដាំ*

១- គួសចំណាំនូវកន្លែងដែលត្រូវធ្វើរង ហើយចាំងស្មៅចេញ ដោយយកស្មៅទុកមួយដុំ សំរាប់ប្រើ ដាក់ចូល ក្នុងរណ្ដៅវិញ ។



២- ជីករណ្ដៅឱ្យបានជំរៅ ៣ តឹក ហើយយកអាចម៍ដីគរទុកមួយដុំ




៣- បន្ទាប់ពីជីកហើយ បំផុសបាតរណ្ដៅ ។



៤- កប់បញ្ចូលនូវស្លឹកឈើ ស្មៅ និងកាកសំណល់រុក្ខជាតិផ្សេងៗ និងលាមកសត្វខ្លះៗឬបន្តិចបន្តួច (ប្រហែល ១/៤ នៃ បរិមាណស្លឹកឈើ) ។



៥- យកអាចម៍ដីមកកប់ពីលើរណ្ដៅវិញទាំងអស់ ហើយកំរាស់ សាច់ដី គឺត្រូវយ៉ាងតិចបំផុត ក៏ប្រវែងមួយចំអាមដែរ ។



៦- យកជីកំប៉ុស្តមកលាយជាមួយអាចម៍ដីនេះ បើអត់ជីកំប៉ុស្ត យើងអាចប្រើលាមកសត្វ ដែលមាន អាយុពីមួយអាទិត្យឡើងទៅ



៧- ស្រោចទឹកលើផ្ទៃរងឱ្យជោគ ។



៨- យកស្លឹកឈើគ្របលើផ្ទៃរង ហើយទុកចោលប្រហែល១ អាទិត្យទៅ ២ អាទិត្យ មុននឹងដាំ ។ នៅពេលដាំ យើងដាំ ពេលល្ងាច ហើយស្រោចពេលព្រឹក ។



៩- ចាប់ផ្តើមដាំបន្ទាប់ពីស្រោចហើយបានប្រហែល ៥ ម៉ោង ក្រោយមក ។ សូមកុំស្រោច

ទឹកថែមទៀត មុនពេលដាំភ្លាម ហើយក្រោយពេលដាំ ។ សូមរក្សាគំរបដីនៅដដែល ។



១០- មួយថ្ងៃ ឬ ២ ថ្ងៃក្រោយមក បើរងមាន សភាពស្ងួត យើងអាចស្រោចទឹកបន្ថែម ។

**កំណត់សំគាល់ផ្សេងៗ ក្នុងការធ្វើរងនេះ**

- ☞ បរិមាណជីលាមកសត្វ គួរតែស្មើប្រហែលមួយភាគបួន នៃសារធាតុសរីរាង្គទាំងអស់ ។
- ☞ បើពិបាកកាប់ចូលទៅជ្រៅខ្លាំង យើងអាចធ្វើជារបៀប ពូនឡើងវិញ ។ យើងអាចប្រើដើមចេកឬ កំណាត់ឈើ ជារបាំងសងខាងរង ដើម្បីងាយស្រួលគរសារធាតុសរីរាង្គ និងពូនដី ។
- ☞ ប្រសិនបើនៅកន្លែងដែលជាដីខ្សាច់ យើងគួរលាយដីដំបូកខ្លះៗ ជាមួយដីដែលពូនជារងខាងលើ

## ៣.៤. របៀបដាក់ជី និងស្រោចទឹកលើចំណាំឈើហូបផ្លែ

បទពិសោធន៍កន្លងមក បានបង្ហាញឱ្យឃើញថា ការធ្វើជាចង្អូរនៅជុំវិញដើមឈើហូបផ្លែសំរាប់ដាក់ជី និង ស្រោចទឹក អាចជួយឱ្យដើមឈើហូបផ្លែលូតលាស់ និងបានផលល្អ ។

ដូចនេះ យើងខ្ញុំសូមលើកយករបៀបអនុវត្តនូវបច្ចេកទេសនេះ មកបង្ហាញដូចតទៅ :

១- យើងត្រូវជីកចង្អូរជារាងរង្វង់ជុំវិញគល់ឈើ ដោយកន្លែងដែលជីកចង្អូរ ត្រូវនៅចំកន្លែងចុងមែករបស់ ដើមឈើឬកូនឈើនោះ ពីព្រោះជាកន្លែងដែលឫសលូតលាស់ដល់ ហើយជាកន្លែងដែលប្រជុំនូវប្រព័ន្ធឫស ដែលស្រូបយកជីជាតិ និងទឹកពីដី (រូបទី១ និងរូបទី២) ។ ទំហំរបស់ចង្អូរគឺ ទទឹង ១ តឹកកន្លះទៅ ២ តឹក ហើយជំរៅប្រហែល ១ តឹកកន្លះទៅ ២ តឹកដែរ ។




**ការជីកចង្អូរជុំវិញដើមឈើ**

២- បន្ទាប់មក យើងប្រមូលយកស្លឹកឈើ លាមកសត្វ និងជីធម្មជាតិផ្សេងៗយកមកដាក់បំពេញតាមចង្អូរនេះ ។ នៅពេលចង្អូរពេញ យើងអាចលាយដីពីលើថែមបន្តិចៗ(សូមប្រើដីស្រទាប់លើ) ។ យើងក៏អាចយក ផេះលាយជាមួយដីបន្ថែមបានដែរ ។

**ការប្រមូលស្លឹកឈើ និងលាមកសត្វដាក់បំពេញចង្អូរ**



៣- នៅពេលយើងស្រោចទឹកបន្ថែម យើងស្រោចតែតាមចង្អូរបានហើយ ។ ប្រសិនបើយើងមានជីទឹកសំរាប់ស្រោចជាការមួយល្អណាស់ ជាពិសេសនៅពេលមុនឈើរៀបចេញផ្កា ឬកំពុងចេញផ្កាបានបន្តិច ។



**ការស្រោចទឹកដើម្បីឱ្យសារធាតុសរីរាង្គឆាប់ពុករលួយ**

៤- ក្នុងរយៈពេល ២-៣ អាទិត្យក្រោយមក សារធាតុសរីរាង្គត្រូវបានពុកបន្តិចម្តង១ ពេលនោះ ជីក្នុងរណ្តៅក៏ស្រុតចុះដែរ ។ ដូចនេះ យើងត្រូវខុសស្សាហ៍ដាក់ជីបន្ថែម ។



**ដើមឈើទទួលផលផ្លែផ្កា**

ដើម្បីចង់ដឹងថា តើវិធីសាស្ត្រដូចរៀបរាប់ខាងលើអាចជួយនាំមកផលល្អ សូមបងប្អូនកសិករធ្វើការជ្រើសរើសឈើហូបផ្លែ (ឧទាហរណ៍ ត្របែក ក្រូចឆ្មារ ពុទ្រា ។ល។) ចំនួន ៤ ទៅ ៥ ដើម ធ្វើការពិសោធន៍ ហើយធៀបជាមួយអ្វីដែលជាទំលាប់របស់បងប្អូន។ យើងសង្ឃឹមថា ការពិសោធន៍របស់បងប្អូនជួបបានលទ្ធផលល្អ ។

## ៣.៥. សួនរង្វង់

### ១) អ្វីទៅជាសួនរង្វង់ ?

សួនរង្វង់ជាសួនមួយដែលមានរណ្ដៅដូចបាតខ្ទះ ហើយមានរងដំណាំព័ទ្ធជុំវិញរណ្ដៅ ។ នៅក្នុងរណ្ដៅ គេដាក់សារធាតុសរីរាង្គ ហើយតាមរងជុំវិញរណ្ដៅនោះ គេអាចដាំដំណាំច្រើនប្រភេទ ។

### ២) ហេតុអ្វីបានជាចាំបាច់ធ្វើសួនរង្វង់ ?

សួនរង្វង់មានលក្ខណៈសមស្រប ពិសេសសំរាប់ការដាំបន្លែផ្គត់ផ្គង់គ្រួសារនៅតំបន់ដែលខ្សត់ទឹក ឬរដូវខ្សត់ទឹក ពីព្រោះបន្ទាប់ពីស្រោចហើយ ទឹកវាប្រមូលផ្ដុំនៅក្នុងរណ្ដៅ ហើយសារធាតុសរីរាង្គដែល នៅក្នុងរណ្ដៅអាចចាប់ និងរក្សាសំណើមបានយូរ ។

នៅតំបន់ដែលមានដីហាប់ពេក ឬឥដ្ឋពេក សួនរង្វង់អាចនាំឱ្យដីផុសបានល្អ ហើយដំណាំងាយស្រួលលូត លាស់ជាងមុន ។

### ៣) តើគេធ្វើសួនរង្វង់យ៉ាងដូចម្ដេច ?

ដំបូង គេជីករណ្ដៅជំរៅពី ២៥ ទៅ ៣០ ស.ម (២ តឹកកន្លះទៅ ៣ តឹក) ហើយកាយយកដីចេញ ដើម្បីយកមកប្រើធ្វើជារងព័ទ្ធជុំវិញរណ្ដៅ ។ រណ្ដៅត្រូវធ្វើឱ្យមានរាងដូចបាតខ្ទះ ហើយបន្ទាត់ផ្ចិតរបស់មាត់រណ្ដៅ ត្រូវមានប្រវែង ១ ម៉ែត្រ ។

រងដែលមានរាងជារង្វង់ព័ទ្ធនៅជុំវិញរណ្ដៅ ត្រូវមានរាងដូចខ្នងអណ្ដើក ដោយបាតរងមានទទឹង ៣ តឹក កំពស់រងមានប្រវែង ២ តឹក ទៅ ២ តឹកកន្លះ និងទទឹងរងផ្នែកខាងលើមានប្រវែង ១ តឹកកន្លះ (សូមមើលរូបភាព) ។



## ៤) តើគេដាក់ជី និងស្រោចទឹកយ៉ាងដូចម្ដេច ?

បន្ទាប់ពីធ្វើសួនរួចហើយ គេបំពេញរណ្ដៅដោយប្រើ*សារធាតុសរីរាង្គ* មានដូចជាស្លឹកឈើ ស្មៅ ចំបើង លាមកសត្វ ។ល។ នៅពេលស្រោចទឹក គេស្រោចតែលើសារធាតុសរីរាង្គ គឺមិនស្រោចលើរង ដែលនៅជុំវិញរណ្ដៅទេ ។ ជាបណ្ដើរៗ រុក្ខជាតិចាប់ផ្ដើមស្រូបយកជីជាតិ និងទឹកពីរណ្ដៅបាន ។ ក្នុងរយៈពេលលូតលាស់របស់ដំណាំ គេត្រូវតែឧស្សាហ៍បន្ថែមសារធាតុសរីរាង្គឱ្យបានញឹកញាប់ ។ សូមបញ្ជាក់ផងថា : ពេលយើងបន្ថែមជី គេធ្វើយ៉ាងណាជៀសវាងដាក់តែជីមួយប្រភេទ ។ យើងត្រូវឧស្សាហ៍-ព្យាយាមលាយជីឱ្យបានច្រើនមុខ ។

## ៥) តើនៅលើរង្វង់ គេដាំដំណាំយ៉ាងដូចម្ដេចដែរ ?

ចំពោះសួនរង្វង់ គេមិនដាំនៅលើរងទេ តែនៅលើផ្នែកទេរខាងក្នុងរបស់រង។ ការដាំ គឺមិនត្រូវឱ្យខិតចុះមកក្រោមពេកដែរ (សូមមើលរូបភាពខាងក្រោម) ។ នៅផ្នែកខាងក្រៅនៃរង គេអាចដាំដំណាំផ្សេងៗ សំរាប់គ្របជី ។ គេអាចដាំដំណាំបានច្រើនមុខនៅតាមរង្វង់មួយ ឧទាហរណ៍ : ដំណាំខ្ពស់ ដំណាំទាប ដំណាំវារឡើងទ្រើង និងដំណាំវារលើដី ។ ដំណាំទាំងនោះមានរបៀបលូតលាស់ផ្សេងៗគ្នា តែស្រូបយកទឹក និងជីពីកន្លែងតែមួយ ។



**របៀបដាំដំណាំនៅលើសួនរង្វង់**

## ៣.៦. ដំណាំជីស្រស់បៃតង

### ក- ជីស្រស់ និងផលប្រយោជន៍របស់វា

ជីស្រស់ ឬជីបៃតង ជាប្រភេទដំណាំដែលគេដាំសំរាប់ជួយដល់ការថែរក្សា និងបង្កើននូវជីជាតិដល់ដី ។

ការដាំជីស្រស់នាំមកនូវផលប្រយោជន៍សំខាន់ដល់ដី :

- គំរបការពារដីទប់ទល់នឹងកំដៅ និងតំណក់ទឹកភ្លៀង
- ឫសរបស់ដំណាំជីបៃតង ជួយធ្វើឱ្យដីផុសបានល្អ និងនាំមកនូវសារធាតុចិញ្ចឹមជាច្រើនដល់សត្វល្អិត ដែលរស់នៅក្នុងដី
- ផ្នែកផ្សេងៗរបស់ដំណាំនៅពេលពុក ក្លាយជាជីសំរាប់រុក្ខជាតិ និងជួយឱ្យដីផុសបានល្អ
- នាំមកនូវសារធាតុចិញ្ចឹម ជាពិសេស ជីអាសូតចូលមកក្នុងដី (ជាពិសេសពពួកកូរ)

### ខ- ប្រភេទរុក្ខជាតិសំខាន់ៗដែលអាចដាំធ្វើជាជីស្រស់បាន

រុក្ខជាតិសំខាន់ៗដែលអាចប្រើជាជីស្រស់បានមានដូចជា សណ្តែកអង្គុយ(គ្រាប់ក្រហម, ស, ខ្មៅ, ពងក្រួច) សណ្តែកខ្មោច និងពពួកសណ្តែក និងពពាយផ្សេងៗទៀត ដោយពពួកនេះ វាមិនសូវត្រូវការជីជាតិច្រើនពីដី វាមានឫសជ្រៅ អាចផលិតនូវស្លឹកបានបរិមាណច្រើនក្នុងរយៈពេលខ្លី និងជាពិសេស អាចនាំមកនូវសារធាតុអាសូតចូលមកក្នុងដី ។



**ដាំពពួកសណ្តែកធ្វើជីស្រស់**

គ- ចំណុចណែនាំសំរាប់ការអនុវត្តការដាំជីស្រស់

- ជ្រើសរើសនូវពពួកដំណាំជីស្រស់ដែលសមស្រប យកល្អធ្វើការសាកល្បងជាមួយសណ្តែកអង្គុយ
- មុនពេល ឬពេលសណ្តែកចាប់ផ្តើមចេញផ្កា កាត់មែកនិងស្លឹកដល់គល់
- បង្កប់ជីស្រស់នេះចូលក្នុងដី ហើយទុកចោលប្រហែល ៣ អាទិត្យមុននឹងដាំ
- ប្រើជីស្រស់គ្របលើដី ហើយបន្ទាប់មកអាចវែកចន្លោះដើម្បីដាំកូនដំណាំ

ការដាំសណ្តែកធ្វើជាជីស្រស់ (កប់ដើមសណ្តែកទៅក្នុងដីមុននឹងដាំស្ពៃ)



☞ សូមជៀសវាងការដាំដំណាំក្រោយពេលការកប់ជីស្រស់ចូលក្នុងដីភ្លាម ពីព្រោះនៅពេលកប់ចូលក្នុងដី ជីស្រស់ចាប់ផ្តើមបំបែកធាតុដែលនាំមកនូវកំដៅប៉ះពាល់ដល់ការលូតលាស់របស់ឫសដំណាំ ។

## ៣.៧. ការដាំបង្វិល

ជារបៀបដាំចំរុះដំណាំ ដែលនៅលើរងមួយ ឬលើកន្លែងមួយ គេធ្វើការផ្លាស់ប្តូរប្រភេទដំណាំ ដោយលៃយ៉ាងណាកុំឱ្យប្រភេទដំណាំដដែល១ដាំនៅលើដីដដែល នៅរដូវបន្ទាប់ ឬឆ្នាំបន្ទាប់ ។

ការដាំបង្វិលនាំមកនូវផលប្រយោជន៍ជាច្រើនក្នុងការការពារដំណាំមិនឱ្យមានការបំផ្លាញពីសត្វល្អិត និងជម្ងឺ និងជួយរក្សាជីជាតិដី ។

**ការការពារដំណាំ**

តាមរយៈការមិនដាំដំណាំដដែល១ ឬដំណាំមកពីក្រុមដដែល១ អាចឱ្យយើងបង្ការឱ្យមានការប្រមូលផ្តុំ និងការផ្ទុះឡើងនូវកត្តាចង្រៃ និងជម្ងឺ ។

**ការថែរក្សាជីជាតិដី**

ដំណាំនីមួយ១ មានតំរូវការនូវសារធាតុចិញ្ចឹមផ្សេង១គ្នា ។ ដូចនេះការផ្លាស់ប្តូរមុខដំណាំ ជៀសវាងមិនឱ្យមានការស្រូបយកអស់នូវសារធាតុណាមួយពីដី ។ ក្រៅពីនេះ បើយើងផ្លាស់ប្តូរមុខដំណាំ ដោយដាំដំណាំដូចជា ពពួកសណ្តែក វាអាចជួយនាំមកនូវសារធាតុចិញ្ចឹមចូលមកដី ។

ការផ្លាស់ប្តូរនូវប្រភេទដំណាំឬសវែង ជាមួយដំណាំឬសខ្លី ក៏អាចជួយដល់ការប្រើប្រាស់នូវសារធាតុចិញ្ចឹមពីស្រទាប់ផ្សេង១របស់ដី ក៏ដូចជាបំផុសដីឱ្យបានល្អដែរ (ពពួកដំណាំដែលមានឬសជ្រៅ) ។




**ការបែងចែកក្រុមដំណាំទៅតាមតំរូវការជីជាតិដី**

## របៀបជ្រើសរើសដំណាំសំរាប់ដាំបង្វិល

ដើម្បីងាយស្រួលក្នុងការបង្វិលមុខដំណាំ យើងចែកដំណាក់ជា ៤ ក្រុមធំៗ :

- ពពួកក្រុមបន្លែយកស្លឹក ( ផ្ទី ត្រកួន ស្ពៃ ។ល ។)
- ពពួកក្រុមយកផ្លែ ( ត្រប់ ប៉េងប៉ោះ ត្រសក់ ។ល ។)
- ពពួកក្រុមយកមើម ( ដំឡូងជ្វា ដំឡូងមី ត្រាវ ខ្ញី ។ល ។)
- ពពួកក្រុមកួរ ( សណ្តែកកួរ ពពាយជ្រុង សណ្តែកអង្គុយ ។ល ។)

ចំណុចសំខាន់ៗ សំរាប់ជ្រើសរើសដំណាំក្នុងការដាំបង្វិល ដែលអ្នកត្រូវដឹងគឺ :

- ពពួកក្រុមបន្លែយកស្លឹក និងយកផ្លែ ត្រូវការជីជាតិច្រើនពីដី
- ពពួកក្រុមយកមើម ត្រូវការជីជាតិមធ្យម
- ពពួកកួរត្រូវការជីជាតិតិច ហើយអាចផ្តល់ជីជាតិដល់ដី ។

ដូចនេះនៅពេលដាំបង្វិល យើងជៀសវាង ឧទាហរណ៍ កុំឱ្យពពួកបន្លែយកផ្លែ និងយកស្លឹកដាំបណ្តាក់ជាប់គ្នា គេគួរឆ្លាស់ជាមួយបន្លែពីក្រុមផ្សេងទៀត ជាពិសេស ជាមួយពពួកកួរ ។

## ៣.៤. ថ្នាំសំលាប់សត្វល្អិតផ្សំពីរុក្ខជាតិ និងការធ្វើឱ្យសត្វល្អិតចង្រៃចាកចេញពីដំណាំ

សត្វចង្រៃ គឺជាអ្នកបង្ហាញ ឬជារោគសញ្ញានៃបញ្ហាផ្សេងៗ ។ បើសិនជាយើងយកចិត្តទុកដាក់លើការធ្វើដីឱ្យបានល្អ ការប្រើប្រាស់ពូជ ឬកូនដំណាំដែលមានសុខភាពល្អ ការអនុវត្តន៍ការដាំដំណាំបង្វិល និងការជ្រើសរើសដំណាំឱ្យសមស្របទៅនឹងដី និងរដូវកាល នោះបញ្ហានៃ*កត្តាចង្រៃ*នឹងកំរកើតមានណាស់ ។

បើសិនយើងបានអនុវត្តតាមរបៀបខាងលើហើយ ក៏ប៉ុន្តែដំណាំរបស់យើងនៅតែទទួលរងការរាតត្បាតពីកត្តាចង្រៃនោះ យើងអាចប្រើថ្នាំដែលផ្សំពីរុក្ខជាតិខ្លះៗដែលអាចយកទៅប្រើដើម្បីរុញច្រាន (បណ្តេញ) ឬធ្វើឱ្យសត្វល្អិតចង្រៃទាំងនេះ លែងចង់ស៊ីដំណាំទៀត ។

ថ្នាំសំលាប់សត្វល្អិតផ្សំពីរុក្ខជាតិ ត្រូវបានធ្វើឡើងពីរុក្ខជាតិ ដែលមានស្លឹកល្វីងខ្លាំង ឬរុក្ខជាតិមានជ័រស្អិតដូចទឹកដោះ (ភាគច្រើនមានជាតិពុល) ឬមានក្លិនខ្លាំង ។ ខាងក្រោមនេះជាឧទាហរណ៍ពីរ :

**រូបភាពខ្លះៗនៃសត្វល្អិតចង្រៃបំផ្លាញដំណាំ**

ដង្កូវ





ត្រឡោកគូ ឬឃ្មុគា

មេខ្មៅសត្វលោតៗ (ឈ្មោះកសិករហៅ)

ខ្យង និងខ្មៅដី





ខ្ចង ឬក្រា (ពាក្យករបស់កសិករ)

កណ្តូប





ដង្កូវស៊ីរូងដើម

រុយ





មេផល្លាក់ស្លឹក ឬក្រា

(ពាក្យរបស់កសិករ)



ដំបំបែកខ្ទឹម ឬស្លឹកគ្រៃ ឬជី ។ល។) ត្រាំក្នុងប្រេងឱ្យបានយ៉ាងតិចពី ៥ ទៅ ៧ ថ្ងៃ ។ នៅពេលបាញ់លាយទឹកថ្នាំនេះ មួយស្លាបព្រាបាយ( ១៥ ម.ល) ជាមួយនឹងទឹកសាប៊ូមួយពែង( ២០ម.ល) រួចបាញ់នៅពេលល្ងាចត្រជាក់ ។



ដំបំបែកស្លឹកទៀបខ្មែរ ល្ហុង ស្ដៅ ។ល។ លាយទឹកពី ៦ ទៅ ៨ ដង រួចត្រាំទុកពីរថ្ងៃ ។ ប្រើមិនបាច់លាយទឹកបន្ថែមទៀតទេ និងបាញ់នៅពេលល្ងាចត្រជាក់ ។

ដើម្បីជាជំនួយដល់លោកអ្នកក្នុងការផ្សំថ្នាំធម្មជាតិ ខ្ញុំសូមជូនឧទាហរណ៍មួយទៀត ដែលជាបទពិសោធន៍ របស់កសិករ **សន សុន** :

ពូ **សន សុង** រស់នៅភូមិសសី ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្ដាល គាត់បានធ្វើថ្នាំផ្សំពីរុក្ខជាតិបានជោគជ័យ ប្រើលើស្ពៃ កាលពីនៅចុងឆ្នាំ ២០០០ ។ ចំពោះលទ្ធផល និងរបៀបធ្វើថ្នាំមានដូចខាងក្រោម :

**រុក្ខជាតិសំរាប់ផ្សំ :** សំបក និងគ្រាប់ស្លែង ៥ គ.ក្រ វល្លិ៍បណ្ដូលពេជ្រ ១ គ.ក្រ កន្ទ្រោបខ្មោច ៣ គ.ក្រ និងទឹកនោម ៥ លីត្រ ។ ធាតុផ្សំទាំងនេះ ត្រូវកាប់ចិញ្ច្រាំ ហើយត្រាំលាយជាមួយទឹកធម្មតា ១៣ លីត្រ ដោយទុករយៈពេល ១៥ ថ្ងៃទើបគាត់យកទៅប្រើ ។ នៅពេលប្រើ គាត់លាយទឹកថ្នាំចំនួន ២ លីត្រ ជាមួយទឹកធម្មតាចំនួន ១០ លីត្រ ដើម្បីបាញ់ទៅលើដំណាំ ។ តាមការសង្កេតរបស់គាត់លើ ប្រសិទ្ធភាព ពេលគាត់បាញ់ហើយមិនសូវឃើញមានសត្វងាប់ទេ តែគាត់ឃើញសត្វវាមិនដែលនៅ ក្នុងរយៈពេល ៣ ទៅ ៥ ថ្ងៃ ទើបគាត់ឃើញសត្វមានចូលខ្លះ ។ ការប្រើថ្នាំនេះ គាត់ឃើញដំណាំរបស់គាត់ល្អ ស្លឹកក្រាស់

និងមានកំលាំង ។ គាត់យល់ថា ថ្នាំនេះអាចជួយកាត់បន្ថយការប្រើថ្នាំពុលគីមីបានទាំងស្រុង ជាពិសេស ចំពោះដំណាំបន្លែ ។

ទោះបីថ្នាំផ្សំពីធម្មជាតិក៏មានប្រសិទ្ធិភាពយ៉ាងណាក៏ដោយ ក៏យើងត្រូវប្រុងប្រយ័ត្នដែរ ។ នៅពេលផលិតនិងប្រើ យើងត្រូវយកចិត្តទុកដាក់លើចំណុចសំខាន់ៗមួយចំនួន :

- ថ្នាំផ្សំពីរុក្ខជាតិក៏មានជាតិពុលដែរ ដូចនេះនៅពេលលាយ និងប្រើ សូមប្រុងប្រយ័ត្ន ជាពិសេស នៅពេលបើកដប ឬពាងត្រាំថ្នាំដំបូង( ក្លិនខ្លាំង)
- ជៀសវាងប្រើថ្នាំជក់ជាវត្ថុធាតុដើម
- ការបាញ់ថ្នាំផ្សំពីរុក្ខជាតិ គ្រាន់តែជាដំណោះស្រាយចុងក្រោយទេ ។ សូមលោកអ្នក យកចិត្ត ទុកដាក់លើវិធានការផ្សេងៗដែលសំរាប់ការពារដំណាំ និងជួយឱ្យដំណាំដុះលូតលាស់បានល្អ ។

## ៣.៩. ជីកំប៉ុស្ត

ក- ជីកំប៉ុស្ត និងសារៈសំខាន់របស់វា

ជីកំប៉ុស្ត គឺជាជីដែលផ្គុំឡើងដោយសារធាតុសរីរាង្គផ្សេងៗ ហើយទុកឱ្យបំបែកធាតុ(ពុក) ក្នុងរយៈពេលកំណត់មួយសិន មុននឹងយកមកប្រើ ។

គោលបំណងសំខាន់នៃការធ្វើជីកំប៉ុស្ត គឺផលិតនូវជាតិ*មរមោក* ដែលជាសារធាតុសំខាន់សំរាប់ដីដោយវាសំបូរទៅដោយសត្វល្អិតដែលផ្តល់ជីវិតដល់ដី សំបូរសារធាតុចិញ្ចឹមជីវិត និងអាចជួយឱ្យដីមានសមត្ថភាពស្រូបយកទឹកនិងជីបានច្រើន ។

ខ- របៀបធ្វើជីកំប៉ុស្ត

ធនធានសំរាប់ធ្វើជីកំប៉ុស្តមាន :

- ធាតុស្ងួត ឬធាតុដែលសំបូរកាបោន ដូចជា : ចំបើង, ស្មៅស្ងួត, ស្លឹកឈើ, អាចម៍រណារ ...
- ធាតុសើម ឬពពួកសំបូរជាតិអាសូត ដូចជា : ស្លឹកឈើស្រស់(ស្លឹកពពួកដំណាំកូរ ឬពពួកសណ្តែក), អាចម៍សត្វ, កាកសំណល់ផ្ទះបាយ
- ដី អាចជាដីស្រទាប់លើ ឬដីដំបូក ឬ ជីកំប៉ុស្តចាស់

នៅពេលធ្វើជីកំប៉ុស្ត គេអាចលាយធាតុទាំង ៣ នេះបាន ២ របៀប :

- រៀបវាជាស្រទាប់ៗ
- លាយចូលគ្នាទាំងអស់តែម្តង
- ជាទូទៅការរៀបស្រទាប់ មានលក្ខណៈប្រសើរជាងការលាយចូលគ្នាទាំងអស់
- ការរៀបជាស្រទាប់ៗ វាមិនទាមទារឱ្យយើងត្រឡប់ទេ(ការត្រឡប់មិនចាំបាច់ទេ) ហើយក៏វាមានភាពងាយស្រួលក្នុងការរក្សាតុល្យភាពរវាងធាតុស្ងួត ធាតុសើមនិងដី

ចំពោះការរៀបជាស្រទាប់ៗ គេអនុវត្តដូចខាងក្រោមនេះ :

ស្រទាប់ទី១ : ធាតុស្ងួត(៣ ដង)

ស្រទាប់ទី២ : ធាតុសើម(២ ដង)

ស្រទាប់ទី៣ : ដី (១ ទៅកន្លះដង)

ការរៀបជាស្រទាប់របៀបនេះរហូតដល់ទ្រុងជី ឬរណ្តៅជីពេញ ។

បរិមាណសារធាតុសំខាន់ៗទាំង ៣ នៅពេលលាយចូលគ្នាធ្វើជាកំប៉ុស្ត



ដី( ដីស្រទាប់លើ ឬដីបាតត្រពាំង ...) លាយ
ជាមួយផេះ និងកំប៉ុស្ត

ធាតុសើម( ពពួកសំបូរអាសូត N)

សារធាតុស្ងួត ពពួកសំបូរកាបូន (C)



ការគ្របទ្រុងដីកំប៉ុស្ត



ទ្រុងដីកំប៉ុស្តដែលធ្វើដំបូលប្រក់ពីលើ



ទ្រុងដីកំប៉ុស្តដែលធ្វើនៅក្រោមដើមឈើ

គ- របៀបប្រើប្រាស់ជីកំប៉ុស្ត

ជីកំប៉ុស្តដែលយើងយកទៅប្រើត្រូវធានាថាវាបានពុក ឬកាច់អស់គ្មានកំដៅ ។ ប្រសិនបើវាមិនទាន់កាច់អស់ទៅ នៅពេលយកវាទៅប្រើ វានឹងបញ្ចេញកំដៅអាចប៉ះពាល់ដល់ឫសដំណាំ (ធ្វើឱ្យដំណាំរលួយ) ។

គេអាចយកជីកំប៉ុស្តប្រើបានច្រើនរបៀប ដូចជា :

- ការប្រើទ្រាប់បាតមុនពេលដាំដំណាំ ដោយយកជីទៅលាយបញ្ចូលក្នុងដីដែលត្រូវដាំ
- យកជីទៅរោយជុំវិញគល់ដំណាំ ឬរងដំណាំនៅពេលវាកំពុងលូតលាស់
- យកជីទៅលាយជាមួយដីសំរាប់ច្រកថង់បណ្តុះកូនឈើ (ប្រើជី ៣ ភាគ លាយជាមួយដី ៧ ភាគ)
- យើងអាចប្រើដើម្បីកែប្រែដីដែលសំបូរខ្សាច់ ឬដីឥដ្ឋខ្លាំងពេកឱ្យទៅជាដីដែលមានភាពស្អិត ឬធូរល្អបាន
- គេអាចយកវាទៅលាយជាមួយទឹក ហើយស្រោចលើដំណាំ ដែលមានលក្ខណៈដូចគ្នានឹងជីកំប៉ុស្តទឹកដែរ ជាពិសេសស្រោចដើម្បីបំប៉នកូនដំណាំ និងមុនពេលដំណាំជិតចេញផ្កា ។ គេអាចប្រើជី ១ គីឡូក្រាម លាយ ជាមួយទឹក ៨ ទៅ ១០ លីត្រ
- គេអាចប្រើវាដាក់ក្នុងស្រះចិញ្ចឹមត្រីដើម្បីបង្កើនការលូតលាស់នៃរុក្ខជាតិនៅក្នុងទឹកដែលជាចំណីត្រី ឬផ្តល់ជាចំណីត្រីផ្ទាល់តែម្តង ។



រោយជីកំប៉ុស្ត ឬលាមក
គោពុកល្អតាមចន្លោះ កូនដំណាំ



ការបាចជីកំប៉ុស្ត ឬ លាមកសត្វទ្រាប់បាត
លើរងស្ពៃមុនដាំស្ពៃ

ឃ- ចំណុចដែលត្រូវចងចាំបន្ថែមនៅពេលធ្វើ និងប្រើជីកំប៉ុស្ត

សរុបមក ដើម្បីផលិតឱ្យបានជីកំប៉ុស្តដែលមានគុណភាពល្អ ត្រូវចងចាំនូវចំណុចណែនាំបន្ថែមមួយចំនួនដូចខាងក្រោម :

- ត្រូវប្រើសារធាតុសរីរាង្គ ឱ្យបានច្រើនប្រភេទសំរាប់ធ្វើជីកំប៉ុស្ត
- ត្រូវរក្សាឱ្យមានតុល្យភាពរវាងធាតុស្ងួតនិងធាតុសើម ជៀសវាងកុំឱ្យធាតុស្ងួតច្រើនពេក ឬសើមពេក
- គំនរជីកំប៉ុស្តត្រូវធានាឱ្យមានខ្យល់ចេញចូល ពីព្រោះវាបង្កឱ្យមានសត្វតូចៗ មានប្រយោជន៍ច្រើនដែលមានតួនាទីសំខាន់ជួយឱ្យជីមានជីជាតិល្អ និងដំណាំលូតលាស់បានល្អ ។ ដើម្បីជួយឱ្យមានខ្យល់ចេញចូលបានល្អ គេត្រូវឧស្សាហ៍ត្រឡប់ជី ។ ម្យ៉ាងវិញទៀត គេអាចដាក់បំពង់ឬស្សីដែលមានប្រហោង ដោតនៅកណ្តាលគំនរជីដើម្បីនាំខ្យល់ចូល ។ គេត្រូវជៀសវាងធ្វើជីក្នុងរណ្តៅដែលមានទឹកដក់ជាប់ ។
- ចំពោះនៅរដូវរាំងស្ងួត ហើយធាតុផ្សំរបស់ជីសំបូរទៅដោយសារធាតុស្ងួត យើងគួរឧស្សាហ៍ស្រោចទឹកបន្ថែមលើជី ។
- រណ្តៅ ឬគំនរជីកំប៉ុស្តត្រូវគ្របឱ្យបានល្អ ដើម្បីការពារកុំឱ្យសារធាតុអាសូតហើរចេញ ។
- ជីកំប៉ុស្តដែលរួចរាល់ហើយសំរាប់ប្រើ មានគុណភាពល្អ គឺ :

  មិនមានក្លិនស្អុយ(មានក្លិនល្អ) មិនក្តៅ រលួយចូលគ្នាអស់(ដោយមិនអាចឱ្យយើងស្គាល់បានថាតើធាតុណាជាធាតុអ្វី)

**"ប្រើជីកំប៉ុស្ត ទើបដីវាផុស ប្រើជីគីមីខុសនាំឱ្យដីវារឹង"**

## ៤. បទពិសោធន៍សំខាន់ៗរបស់កសិករក្នុងការដាំបន្លែ

### ៤.១. ការដាំល្ហុងអោយបានផ្លែច្រើន ( ដោយ : តាក់ សុខ និង អ៊ី ណារុន)



អ៊ុំប្រុស ជួន ជន អាយុ ៥៩ឆ្នាំ ជាកសិកររស់នៅភូមិជីបាល ឃុំជីបាល ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ កាលពីឆ្នាំ២០០២ រូបគាត់ត្រូវបានអង្គការ **សេដាក** អញ្ជើញឱ្យទៅធ្វើទស្សនកិច្ចសិក្សានៅកសិដ្ឋានរបស់កសិករ **ប្រាក់ ច្រេស** រស់នៅភូមិតាសួន ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ។ ក្រោយពីបានធ្វើទស្សនកិច្ចសិក្សាបានស្គាល់ បានឮ និងបានឃើញជាក់ស្តែងផ្ទាល់នឹងភ្នែកមក គាត់បានទទួលគំនិតយ៉ាងច្រើនយកមកកែប្រែលើការងារដាំដុះរបស់គាត់ ដូចជាការដាំល្ហុង ដែលពីមុនមកគាត់ដាំល្ហុងមានដើមខ្ពស់ៗហើយពុំសូវមានផ្លែ។ បច្ចេកដាំរបស់គាត់បង្ហាញ ដូចខាងក្រោម :



- ធ្វើការបណ្តុះ កូន មុនទុកក្នុងកន្ទោងរយះពេល ១ ខែ
- កាប់រណ្តៅទំហំ ៣តឹក បួនជ្រុងនិងជំរៅ៣ តឹកបន្ទាប់មក យកលាមកសត្វពុកផុយ និងកំទេចកំទីសំរាមចាក់ឱ្យបានកន្លះរណ្តៅ រួចយកបន្ទះក្បឿង ១បន្ទះ ទំហំ១,៥តឹក បួនជ្រុងក្នុងរណ្តៅ រួចបន្ថែមជីលាមកសត្វពុកផុយ និងដីមានជីជាតិដាក់ឱ្យពេញរណ្តៅ
- យកកូនល្ហុងដែលបានបណ្តុះហើយ ដាក់ដាំក្នុងរណ្តៅឱ្យចំកណ្តាលរណ្តៅលៃយ៉ាងណាឱ្យឫសចាក់ចំបន្ទះ ក្បឿង ។
- ក្រោយពីដាំហើយ ធ្វើការថែទាំដោយស្រោចស្រពរហូតដល់ល្ហុងចាប់ឫស គាត់ចាប់ផ្តើមជ្រុំគល់ (តាមរង្វង់ស្លឹក) រួចយកចំបើងពុកៗ ឬស្លឹកឈើងាប់គ្របពីលើគល់ល្ហុង ។

តាមរយៈវិធីសាស្ត្រខាងលើនេះ គាត់សង្កេតឃើញថាល្ហុងមានដើមទាបៗហើយផ្លែច្រើនទៀតផង។ ដោយសារបានទទួលបទពិសោធន៍ពីកសិករ **ប្រាក់ ច្រេស** ដែលធ្វើឱ្យគាត់បង្កើនទិន្នផលដំណាំបាន ទាំងស្រូវ បន្លែ និងឈើហូបផ្លែគ្រប់បែបយ៉ាងជួយឱ្យជីវភាពគាត់បានល្អប្រសើរជាងមុន ។

ជាទីបញ្ចប់ គាត់សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់អង្គការ **សេដាក** និងកសិករ **ប្រាក់ ច្រេស** ដែលផ្តល់គំនិតល្អៗដល់គាត់ក្នុងការបង្កើនផលិតកម្មដំណាំ។ គាត់សូមជូនពរឱ្យអង្គការ**សេដាក** និងកសិករ **ប្រាក់ ច្រេស** ជួបប្រទះតែសេចក្តីសុខ និងសេចក្តីចំរើនគ្រប់ប្រការ ។

## ៤.២. បទពិសោធន៍ក្នុងការដាំល្ពៅ ( ដោយ : ជា ឈួន )

លោកពូ **តែម ឌុច** អាយុ ៦៣ ឆ្នាំ ជាកសិកររស់នៅភូមិត្រពាំងឈូក ឃុំពោធិអង្គ្រង ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។ ជាទូទៅ ក្រោយពីការធ្វើស្រែវស្សារួច គាត់តែងមានទំលាប់ដាំដំណាំផ្សេងៗ ដូចជា ឪឡឹក សណ្តែក ល្ពៅ ។ល។ តែចំពោះល្ពៅវិញ គាត់ដាំបានល្អជាងដំណាំផ្សេងៗ ។

ដូច្នេះ យើងសូមលើកយកបទពិសោធន៍ដាំល្ពៅរបស់គាត់មកចែកជូនកសិករទុកជាគំនិតសាកល្បង តាមដូចខាងក្រោម :

### ១. ការរៀបចំដី

ក្រោយពីប្រមូលផលស្រូវរួច គាត់ទុកដីឱ្យស្រស់ទឹកបន្តិច ទើបច្រូតគល់ជញ្ជ្រាំងប្រមូលដាក់ហាលថ្ងៃរយៈពេល ៣ ទៅ ៤ ថ្ងៃ ឱ្យស្ងួតរួចដុតជះបាចលើស្រែ ។ បន្ទាប់មកភ្ជួរលុប ហើយរាស់បំបែកដីហាលចោលរយៈពេល ៧ ទៅ ១០ ថ្ងៃ ដូចលើកទី ១ ដែរ ។ ចំពោះការភ្ជួររាស់លើកទី ៣ គឺភ្ជួរលើកជារងដែលមានចន្លោះពីរងមួយ ទៅមួយប្រវែង ២ ម៉ែត្រ ។ ដីដាំល្ពៅនេះមានទំហំប្រហែល ៧ អារ ។

### ២. ការរៀបចំរណ្តៅសំរាប់ដាំ

ក្រោយពីភ្ជួររួចហើយ គាត់បានកាប់រណ្តៅ ទំហំ ២ តឹកបួនជ្រុង និងជំរៅ ២ តឹកចន្លោះ ពីរណ្តៅមួយទៅមួយចំងាយ ៥ តឹក ។

### ៣. របៀបដាំ

តាមបទពិសោធន៍កន្លងមកគាត់បានយក *គ្រាប់ដែលពុះចេញពីផ្លែសំរាប់ទុកពូជយកទៅដាំភ្លាមៗ*។ គាត់ ជ្រើសរើសគ្រាប់ដែលថ្លោសល្អ *មិនស្វិត* យកទៅដាំដើម្បីឱ្យឆាប់ដុះពន្លក ។




**របៀបរៀបចំរណ្តៅសំរាប់ដាំល្ពៅ**

ក្រោយពីកាប់រណ្តៅហើយ គាត់បានដាក់ជីធម្មជាតិ ( កំប៉ុស្ត-លាមកសត្វ ) នៅបាតរណ្តៅច្របល់លាយជាមួយដីឱ្យសព្វ ស្រោចទឹកក្នុងរណ្តៅឱ្យជោគ រួចកាយដីលុបឱ្យស្មើទើបយកគ្រាប់ទៅដាំ។ *ក្នុង ១ រណ្តៅ គាត់ដាំ ៣ គ្រាប់ ដោយតំរៀបគ្រាប់ជាជួរ* ។ ក្រោយពីដាំហើយគាត់មិនស្រោចទឹកទៀតទេ ព្រោះបានស្រោចនៅពេលរៀបចំរណ្តៅ ដាក់ជីរួចហើយ ។

## ៤. របៀបប្រើជី

ក្នុងមួយខួបជីវិត នៃការដាំដុះល្ពៅគាត់ប្រើជី ចំនួន ២ ដងគឺ :

**លើកទី១** : ប្រើជីលាមកគោក្រៀម ឬកំប៉ុស្តទ្រាប់បាតដាក់ក្នុងរណ្តៅក្នុងកំរិតពី ០.៥ ទៅ ១ គីឡូក្រាម ។

**លើកទី២** : ប្រើជីបំប៉ន (ជីធម្មជាតិសុទ្ធ) បរិមាណដែលប្រើ គឺលើសពីជីទ្រាប់បាត ២ ទៅ ៣ ដង _*ការដាក់ជីលើកទី ២ ចំងាយឃ្លាតពីគុម្ពល្ពៅ ២ តឹក ដោយយកជីទៅរោយត្រង់ចង្អូរដែលភ្ជួរសងខាងគុម្ពល្ពៅនោះ រួចភ្ជួរដីបកចូល លុបលើចង្អូរនោះវិញ* ។




**របៀបរៀបចំរងដាំល្ពៅ**

## ៥. ការថែទាំ

### ក. ការជួសកូន

ក្រោយដាំបានរយៈពេល ១០ ថ្ងៃ គាត់ចាប់ផ្ដើម*ដករំលោះកូនចេញខ្លះ* ដោយជ្រើសរើសតែកូនល្ពៅណាដែលមាន*សុខភាពល្អ* ទៅជួសក្នុងរណ្ដៅដែលមិនដុះ ។ ការជួសដោយកូនល្អជាងការជួសដោយគ្រាប់ ព្រោះធ្វើឱ្យ ល្ពៅដុះបានស្មើគ្នាល្អ ។

### ខ. ការស្រោចទឹក

នៅពេលសង្កេតឃើញថាដីស្ងួតខ្លាំង គាត់ស្រោចទឹកដាក់តាមគុម្ពល្ពៅឱ្យជោគ ឬក៏*បូមទឹកដាក់តាមចង្អូរ ចន្លោះរង ដើម្បីឱ្យវាជ្រាបទៅតាមគុម្ព* ។ ក្រោយពីស្រោចទឹកលើកទី ១ បានរយៈពេល ១៥ ថ្ងៃ ទៅ ២០ ថ្ងៃ ក្រោយមក បើដីស្ងួតខ្លាំងយើងអាចធ្វើការស្រោចម្ដងទៀត ។ ប៉ុន្តែបើមានភ្លៀងមិនចាំបាច់ធ្វើការស្រោចស្រពទេ ។

### គ. ការកាត់ទង និងផ្លែ

នៅក្នុងដំណាក់ការលូតលាស់ បើយើងសង្កេតឃើញ*ទងណាមួយមានផ្លែកាន់ប៉ិនកដៃ ឬក៏ភ្នួនដៃត្រូវកាត់ត្រួយចេញដើម្បីឱ្យផ្លែវាធំល្អ* ហើយបើទងណាមានផ្លែ ២ យើងត្រូវ*បេះផ្លែមួយចេញ* គឺ*បេះផ្លែណាដែលលូតលាស់តូចជាងគេ* ដើម្បីឱ្យផ្លែដែលយើងចង់រក្សាទុក*លូតលាស់បានល្អ* ។



**កាត់ត្រួយ និងបេះផ្លែណាដែលតូចៗចេញខ្លះ**

### ឃ. ការកំចាត់សត្វល្អិត

សត្វល្អិតតែងតែបំផ្លាញដំណាំ ក្នុងដំណាក់កាលលូតលាស់ខុសៗ គ្នា ។ យ៉ាងណាមិញ ចំពោះល្ពៅរបស់លោកពូ មាន*សត្វអណ្តើកមាស*បំផ្លាញក្នុងដំណាក់កាលល្ពៅដុះបានស្លឹក២ ទៅ ៣ ។ លុះដល់ដំណាក់កាលល្ពៅបោះទងមាន*ដង្កូវបំផ្លាញ*។ ប៉ុន្តែវាមានតិចតួចប៉ុណ្ណោះ ព្រោះនៅក្នុងភូមិគាត់មានសត្វ*សារិកាកែវច្រើន*មកចឹកស៊ីដង្កូវ ។ ម្យ៉ាងទៀត *គាត់ជ្រើសរើសពេលវេលាដាំបានសមស្របចន្លោះខែមករា និងខែកុម្ភៈដែលពុំសូវជួបប្រទះនឹងសត្វ ល្អិតបំផ្លាញច្រើន* ។

### ៦. ការប្រមូលផល

ដំណាំល្ពៅផ្តល់ផលបានទាំងផ្លែ ទាំងស្លឹក ផ្លែល្ពៅអាចប្រមូលផលបាននៅពេលមានអាយុ៥០ថ្ងៃ។ ចំណែកទងត្រួយ និងផ្កាអាចបេះបានរៀងរាល់ថ្ងៃ ។ ក្នុង ១ ខួបជីវិតរបស់វា យើងអាចបេះទងផ្កាលក់បាន ១០ ទៅ ១៥ ដង ។

ចំពោះផ្លែ គាត់អាចលក់បាន ៥០០ រៀល ក្នុង ១ ផ្លែ រីឯស្លឹកត្រួយ និងផ្កាបាន ៨០០ រៀល ក្នុង ១ ដុំ ។ ជាទូទៅក្នុង ១ គុម្ពផ្លែល្អដែលអាចទទួលបានមានពី ៥ ទៅ ៦ ផ្លែ ។

សរុបមក បច្ចេកទេសដាំល្ពៅឱ្យបានផ្លែច្រើន របស់គាត់មាន :

- ☞ ជ្រើសរើសពេលវេលាដាំឱ្យបានសមស្រប(ខែមករា-កុម្ភៈ)ដើម្បីកាត់បន្ថយការបំផ្លាញរបស់សត្វល្អិត
- ☞ ភ្ជួរដីហាលចោលរយៈពេល ៧ ទៅ ១០ ថ្ងៃឱ្យ បានចំនួន ២ លើក
- ☞ កាប់រណ្តៅជ្រៅល្មមទំហំ ២ តឹក ៤ ជ្រុង ជំរៅ ២ តឹក ដាក់ជីធម្មជាតិទ្រាប់បាត
- ☞ រក្សាទុកពូជគ្រាប់ល្ពៅទាំងផ្លែ ដោយពុះយកគ្រាប់នោះទៅដាំភ្លាម
- ☞ ដាំក្នុង១ រណ្តៅ ៣ គ្រាប់ ដោយកប់គ្រាប់ត្រង់ជួរ
- ☞ នៅពេលកូនល្ពៅដុះ ដើរដករំលោះយកកូនចេញខ្លះ ហើយជួសកូនទៅរណ្តៅណាដែលមិនដុះ
- ☞ ស្រោចទឹកដាក់តាមគុម្ពល្ពៅ ឬចង្អូររង ២ ថ្ងៃ ម្តងនៅពេលចាប់ផ្តើមដាំ ពេលល្ពៅដុះធំ (បោះដៃស្រោចទឹក ១០ ទៅ ១៥ ថ្ងៃម្តង) បើមានភ្លៀងមិន ចាំបាច់ស្រោចទឹក
- ☞ កាត់ត្រួយនៅពេលល្ពៅចេញផ្លែ និងកាត់ផ្លែចេញខ្លះ ទុកតែផ្លែ១ ក្នុង ១ ទង ដើម្បីឱ្យផ្លែដែលដុះមកលូតលាស់ល្អ ។

## ៤.៣. បទពិសោធន៍ដាំដំណាំត្រាវ (ដោយ : ឡាំ មយូរិទ្ធិ)

លោកពូ ឡឹក ថុល មានអាយុ ៤៧ ឆ្នាំ រស់នៅក្នុងភូមិព្រៃកតាប្រាក់ ឃុំតាលុន ស្រុកស្អាង ខេត្តកណ្តាល គាត់មានមុខរបរដាំដំណាំ និងធ្វើស្រែចំការច្រើនឆ្នាំមកហើយ ។ ក្នុងការដាំដំណាំ គាត់មានបទពិសោធន៍យ៉ាងល្អទៅលើការដាំដុះដំណាំត្រាវ ។ ជារៀងរាល់ឆ្នាំគាត់តែងតែទទួលប្រាក់ចំណូលយ៉ាងច្រើនពីការដាំត្រាវជាងដំណាំផ្សេងៗទៀតដែលគាត់បានដាំ ។ ដូច្នេះដើម្បីជាគំនិតសំរាប់ចែកជូនបងប្អូនកសិករ យើងសូមលើកយកបទពិសោធន៍ របស់ លោកពូបង្ហាញជូនដូចខាងក្រោម :

### ១. របៀបបណ្តុះកូន

មុនពេលដាំផ្ទាល់នៅចំការគាត់បានបណ្តុះកូនឱ្យដុះជាមុនសិន ។ ដើម្បីបណ្តុះកូន គាត់បានរៀបចំថ្នាលដែលមានសុទ្ធតែ*ដីខ្សាច់ ដើម្បីងាយស្រួលក្នុងការដកកូនកុំឱ្យដាច់ឫស ហើយការបណ្តុះកូននេះ មានរយៈពេលពី ២០ ថ្ងៃ ទៅមួយខែ* ។

ក្នុងការបណ្តុះកូនគេប្រើមើម ដោយជ្រើសរើសមើមណាដែលមានពន្លកល្អ ។ ចំណែកបច្ចេកទេសបណ្តុះមានពីររបៀបគឺ : យើងអាចកប់មើមដោយដាក់ក្បាល មើមចុះមកក្រោម និងដាក់មើមកប់ដាំជាម្មតា ។



**កូនត្រាវដែលបណ្តុះហើយ**

### ២. ការរៀបចំដី

ផ្ទៃដីដាំដំណាំត្រាវរបស់ពូមាន ២ កន្លែង គឺ មួយកន្លែងទំហំ ២៤០០ ម៉ែត្រការ៉េ និងមួយកន្លែងទៀតទំហំ ២៨០០ ម៉ែត្រការ៉េ ។

លោកពូមានវិធីសាស្ត្ររៀបចំដីខុសពីគេ ដោយគាត់*ភ្ជួរដីឱ្យបានរួចមុនពេលទឹកឡើងភ្ជួរចំនួន ៥ ដង ហើយ ជ្រៅថែមទៀត* លុះដល់ទឹកស្រក គាត់កាប់បំផុសដីជារណ្តៅដាំតែម្តង ។ ចំណែកឯកសិករដទៃទៀត ភ្ជួរដីក្រោយ ពេលទឹកស្រកភ្ជួរហើយទើបកាប់រណ្តៅដាំ ។

៣. វិធីដាំ

នៅពេលកូនត្រាវមានអាយុ ២០ ទៅ ៣០ ថ្ងៃ និងកំពស់ ១ តឹកកន្លះ ពូចាប់ផ្តើមដកកូនទាំងនោះយកមកដាក់ដាំក្នុងរណ្តៅ ។ បន្ទាប់មកយកកំប្លោកមកគ្របដាក់ក្បែរៗគល់ត្រាវ ដើម្បីជាគំរបដី និងជាជីធម្មជាតិផងនៅពេលដែលកំប្លោករលួយ ។

## ៤. ការថែទាំ

ដើម្បីឱ្យបានទិន្នផលខ្ពស់ លោកពូមានការ យកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការថែទាំដូចជា :

- ធ្វើការដកស្មៅ ( ក្នុងមួយវដ្តលូតលាស់របស់ត្រាវ គាត់ដកស្មៅតែពីរដងប៉ុណ្ណោះ ដោយសារគាត់បានប្រើគំរប កំប្លោកគ្របនៅលើគល់ត្រាវ)
- ចំពោះការដាក់ជី គាត់ដាក់នៅពេលកាប់រណ្តៅដាំ និងដាក់ជីបំប៉ននៅចន្លោះចង្អូររងក្បែរៗរណ្តៅជីដែលគាត់ ប្រើមានលាមកសត្វកំប៉ុស្ត និងគំរបកំប្លោកដែលរលួយ
- ស្រោចទឹក ដោយប្រើម៉ាស៊ីនបូមទឹកបាញ់ដាក់សើមៗដី ជៀសវាងដក់ទឹកដែលនាំរលួយដល់គល់ត្រាវ
- ធ្វើការកំចាត់សត្វល្អិតដែលមកបំផ្លាញដំណាំត្រាវ ដូចជាដើរចាប់ដង្កូវស៊ីស្លឹក កាត់ដើមដែលត្រូវបំផ្លាញ ដោយសត្វល្អិតចោលឆ្ងាយពីចំការ ឬដុតចោល ។
- ធ្វើការតាមដានចំពោះជំងឺក្រាទឹក បើមានកើតលើដើមណា គាត់ឆាប់ដកចោលភ្លាមជៀសវាងឆ្លងទៅដើមដទៃ ទៀត ។

## ៥. ការប្រមូលផល

ដំណាំត្រាវឱ្យផលក្នុងរយៈពេលប្រហែល៦ ខែបន្ទាប់ពីដាំ ។ ចំណែកឯការប្រមូលផលនេះ គឺគាត់ធ្វើការ ជីកគល់យកមើមទាំងតូចទាំងធំ ដោយឱ្យ*ជាប់ដីបន្តិចបន្តួចផងនៅជាប់នឹងមើម* ។ ចំណែក ឯធាង និងស្លឹកគាត់កាត់ចោល ។ លោកពូប្រមូលផលត្រាវរបស់គាត់សរុបចំការទាំងពីរបានទិន្នផល ៧ តោន ។

## ៦. ការថែរក្សាផលត្រាវ

ប្រសិនបើនៅពេលដល់រដូវប្រមូលផលចំពេលដែលតំលៃនៅលើទីផ្សារធ្លាក់ចុះទាប គាត់មិនទាន់លក់ភ្លាមទេ ។ គាត់រក្សាមើមត្រាវទុករហូតតំលៃលើទីផ្សារឡើងបន្តិចវិញ ។ ចំណែកឯរបៀបរក្សាទុកមានដូចខាងក្រោម :

- ដំបូងធ្វើរោងសំរាប់ដាក់ត្រាវ ដោយមានដំបូល ប្រក់ពីធាងដូង ប្រក់រង្វើលឱ្យមានចេញជាម្លប់ខ្លះៗ
- រៀបមើមត្រាវដាក់កុំឱ្យគរលើគ្នាច្រើនពេក បន្ទាប់មកបាចដីល្បប់លុបមើមត្រាវតិចៗ
- ធ្វើការស្រោចទឹកតិចៗនៅពេលដីដែលកប់លើត្រាវនោះស្ងួត ។ ការធ្វើបែបនេះអាចរក្សាទុកបានរយៈពេល ១ខែ ។

សរុបមក បទពិសោធន៍ដាំត្រាវរបស់លោកពូមាន :

☞ ភ្ជួរដីឱ្យជ្រៅទុកមុនពេលទឹកឡើងដើម្បីឱ្យដីធូរ នៅពេលទឹកស្រកកាប់បំផុសដីជារណ្តៅដាំ

☞ បណ្តុះកូនមុនពេលយកទៅដាំនៅចំការ ដោយ ជ្រើសរើសមើមត្រាវដែលមានពន្លកដុះល្អ

☞ រៀបចំថ្នាលបណ្តុះមើមដោយប្រើដីខ្សាច់ដើម្បីងាយស្រួលដកយកកូនទៅដាំ (ដកធូរមិនដាច់ឫសចំណាយ ពេលតិចក្នុងការដកកូន)

☞ ដកកូនយកទៅដាំនៅចំការនៅពេលត្រាវអាយុ ២០ ទៅ ៣០ ថ្ងៃក្រោយបណ្តុះ

☞ ប្រើគំរបកំប្លោកស្ងួតគ្របដី និងគល់ត្រាវ

☞ ថែទាំដោយបោចស្មៅ ជួយដី ដាក់ជីបំប៉នទៅ ក្បែររណ្តៅ

☞ ធ្វើការស្រោចទឹកឱ្យសើមដីជានិច្ច តែកុំឱ្យជាំ ទឹកនាំឱ្យរលួយគល់

☞ ធ្វើការកំចាត់សត្វល្អិត និងជំងឺដោយចុះចាប់ដង្កូវនឹងដៃ ហើយដើរដកចោលនូវដើមណាដែលបំផ្លាញដោយជំងឺ និងសត្វល្អិត

☞ ប្រមូលផលដោយដកយកមើមឱ្យជាប់ដីខ្លះ

☞ រក្សាទុកត្រាវក្នុងរោងប្រក់ដំបូលមានខ្យល់ ចេញចូល

☞ យកដីល្បប់គ្របលើគល់ត្រាវ ហើយបាញ់ទឹកផ្សើមឱ្យសើមជាប់កុំឱ្យស្ងួត ។

## ៤.៤. បទពិសោធន៍ដាំប៉េងប៉ោះ (ដោយ : ស៊ិន អង្គារសោធ)

កសិករ **ប្រាក់ ប្រេស** រស់នៅភូមិតាសួន ឃុំត្រពាំងធំ ខាងជើងស្រុកត្រាំកក់ ខេត្តតាកែវ គាត់មានបទពិសោធន៍ដាំប៉េងប៉ោះបានផ្លែច្រើន ។ បទពិសោធន៍នេះបង្ហាញជូនដូចខាងក្រោម :

✱ បច្ចេកទេសដែលគាត់បានអនុវត្តន៍កន្លងមក

### ក. ការរៀបចំគ្រាប់ដាំ

មុនសាបគ្រាប់ គាត់ធ្វើការបណ្ដុះគ្រាប់ជាមុនដោយយកគ្រាប់ទៅខ្ចប់ក្រណាត់ក្របួចចងឱ្យជាប់ ហើយ ដាក់ត្រាំទឹករយៈពេល ១ យប់ និង ផ្អាប់ ១ យប់ ដើម្បីឱ្យគ្រាប់បឺតទឹក ទើបយកគ្រាប់ទៅបណ្ដុះក្នុងថ្នាល ។

### ខ. ការរៀបចំដីដាំ និងការដាំ

ក្នុងការរៀបចំដី គាត់ភ្ជួររាស់ ឬកាប់បំបែកដីឱ្យម៉ដ្ឋ ទើបរៀបចំលើកជារង ។ ក្នុងការរៀបចំដីដាំនេះវាអាស្រ័យទៅតាមរដូវ ។ នៅរដូវវស្សា គាត់រៀបចំរងដែលមានទទឹង០.៥ ម៉ែត្រ និងបណ្ដោយទៅតាមស្ថានភាពដី ។ នៅលើរងគាត់កាប់ដីជារណ្ដៅចុះក្រោមពី ២ ទៅ ៣ ចប បន្ទាប់មកពូនជារាងខ្នងអណ្ដើកទើបយកចបជីកដាំ ។ ចន្លោះពីដើមមួយទៅដើមមួយ កន្លះម៉ែត្រ និងចន្លោះ ពីរងមួយទៅរងមួយ ៨ តឹក ។

រដូវប្រាំង គាត់លើករងដាំដូចនៅរដូវវស្សាដែរ ប៉ុន្តែការជីករណ្ដៅដាំខុសគ្នាដោយជីកជា*រាងកំពែង* (មានជីកចង្អូរជុំវិញ ដាំសំរាប់ឱ្យទឹកដក់នៅពេលស្រោច) ។ *នៅចន្លោះដើមប៉េងប៉ោះគាត់ដាំដំណាំចំរុះផ្សេងៗ ទៀតដូចជា ម្រះព្រៅ ស្លឹកខ្ទឹម ជីនាងវង និងផ្កា ដែលមានពណ៌ស្រស់ៗ* ដើម្បីទាក់ទាញសត្វមានប្រយោជន៍ដូចជាឃ្មុំជាដើម ។ មុននឹងគាស់កូនប៉េងប៉ោះពីថ្នាលដាំ គាត់ស្រោចទឹកលើថ្នាលឱ្យជោគសិន ។ ការគាស់កូនដាំត្រូវធ្វើទៅពេលល្ងាចដើម្បីកុំឱ្យអន់ដើម ។

### គ. ការប្រើគំរបគ្របគល់ដំណាំ

បន្ទាប់ពីស្ទូងកូនហើយ គាត់ប្រើគំរបគ្របលើគល់ដំណាំទាំងនៅរដូវប្រាំង និងរដូវវស្សា ។ ចំពោះរដូវវស្សា គាត់ប្រើគំរបដើម្បី*ការពារដំណក់ទឹកភ្លៀងខ្ទាតដីមកលើបណ្ដូលប៉េងប៉ោះ* ធ្វើឱ្យបណ្ដូលរួញ ។




ប៉ុន្តែត្រូវឧស្សាហ៍ ប្រមូលគំរបចេញនៅពេលមានពន្លឺថ្ងៃ ដើម្បីកុំឱ្យដំណាំជាំទឹកខ្លាំងដែលអាចបណ្ដាលឱ្យមានជំងឺផ្សិត ។ ចំណែករដូវប្រាំង គាត់ប្រើគំរបគ្របគល់ដំណាំ ដើម្បីរក្សាសំណើមក្នុងដី ។

**ឃ. ការដាក់ជី**

ចំពោះការដាក់ជី គាត់បានយកប្រភេទជីដែលបានពុកផុយរលួយដូចជាជីកំប៉ុស្ត ជីលាមកសត្វពុកផុយ និងជីដែលនៅស្រទាប់ដីផ្នែកខាងលើដាក់លាយបញ្ចូលគ្នា ។ នៅពេលដាំ គាត់ដាក់ជី ១ បង្គីសំរាប់ ៣ រណ្ដៅ ជីបំប៉នគាត់ដាក់ក្រោយពីដាំបានរយៈពេល ២០-២៥ ថ្ងៃ ដោយជ្រុំគល់ដាក់ជីបន្ថែម ដើម្បីជួយដល់ការលូតលាស់របស់ដំណាំ ដោយ ១ គុម្ព ដាក់កន្លះបង្គី ។ លុះដល់ប៉េងប៉ោះអាយុ ៥០ ថ្ងៃ គាត់ជ្រុំគល់ដាក់ជីមួយសាទៀត សំរាប់ជំនួយ ដល់ការលូតលាស់របស់ផ្លែឱ្យថ្លោសធំល្អ និងមានរសជាតិឆ្ងាញ់។

**ង. ការស្រោចទឹក**

នៅរដូវប្រាំងត្រូវស្រោចទឹកមួយថ្ងៃពីរដង ព្រឹកនិងល្ងាច។ ចំពោះរដូវវស្សាយើងស្រោចម្ដងៗ នៅពេលគ្មានភ្លៀង(រាំង)។ ជាពិសេសនៅពេលប៉េងប៉ោះចេញផ្កាត្រូវផ្ដល់ទឹកឱ្យបានគ្រប់គ្រាន់ដើម្បីឱ្យមានផ្លែច្រើន និងធំល្អ។

**ច. ការដោតជ្រលង់**

គាត់ប្រើឫស្សី ដើមអង្កាដីតូចៗ ធ្វើជាជ្រលង់ដោត នៅពេលដែលប៉េងប៉ោះមានអាយុ ២០ ថ្ងៃក្រោយពីដាំដើម្បីទប់ *ដើមកុំឱ្យដួលនៅពេលប៉េងប៉ោះផ្លែ* ជៀសវាងការខាតបង់ទិន្នផល ។ យើងបន្តធ្វើការថែទាំរហូតដល់ប៉េងប៉ោះអាយុ ៣-៤ ខែ ពេលនោះប៉េងប៉ោះនឹងមានផ្លែរហូត ប៉ុន្តែទំហំផ្លែតូចជាងមុន ។

## ឆ. ការថែរក្សាទុកពូជ

ពូជដែលគាត់ដាំនេះ មានប្រភពទិញមកពីផ្សារ ដោយគាត់ទិញផ្លែប៉េងប៉ោះដែលទុំ និងធំល្អមករក្សាទុកដាំបន្តរហូត ។ នៅពេលទុកពូជ គាត់ជ្រើសរើសយកប្រភេទផ្លែដែលទុំនៅសាទី ២ ដោយរក្សាទុកឱ្យទុំនៅនឹងដើមចាំបេះវាយកមកទុក ។ ការទុកដាក់នៅពេលបេះមក គាត់ច្របាច់យកតែគ្រាប់ លាងទឹកឱ្យស្អាត ហាលថ្ងៃឱ្យស្ងួត ( ថ្ងៃស្រទន់) ទើបខ្ចប់ក្រណាត់ចងព្យួរថែរក្សាទុក ។



**ប៉េងប៉ោះនោតប្រលង់ក្រោយរយៈពេល ២០-២៥ ថ្ងៃ**

## ជ. ការប្រមូលផល

ការប្រមូលផលគាត់ចាប់ផ្តើមតាំងពីប៉េងប៉ោះអាយុ ១ ខែឡើងទៅ។ គាត់ប្រមូលផលបាន ៥ សា ក្នុងមួយសាៗបានពី ៣០ ទៅ ៣៥ គីឡូក្រាម នៅលើផ្ទៃដី ៥០ ម៉ែត្រការ៉េ ។ ផលដែលបានមក ក្រៅពីទុកហូបចុកក្នុងគ្រួសារ គាត់លក់ឱ្យទីផ្សារ ។

**សរុបមកបទពិសោធន៍ល្អៗ ក្នុងការដាំប៉េងប៉ោះមាន :**

- មុនសាប បណ្តុះគ្រាប់ ដោយយកក្រណាត់ក្របួចចងឱ្យជាប់ ដាក់ត្រាំទឹក ១ យប់ ផ្អាប់ ១ យប់
- ភ្ជួរដីឱ្យបានផុស និងជ្រៅល្អ
- រដូវវស្សា ជីករណ្តៅដាំជាក់ពែងជុំវិញ ដើម្បីឱ្យទឹកដក់នៅពេលស្រោច
- មុនគាស់កូនប៉េងប៉ោះពីថ្នាលសាប ត្រូវស្រោចទឹកលើថ្នាលឱ្យជោគសិន
- ការគាស់កូនដាំ ត្រូវធ្វើនៅពេលល្ងាច ដើម្បីកុំអោយអន់ដើម

- ដាំដំណាំចំរុះ ដែលមានក្លិននៅចន្លោះដើមប៉េងប៉ោះ ដូចជា ម្រេះព្រៅ ស្លឹកខ្ទឹម ជីនាងវងផ្កា ដើម្បីទាក់ ទាញសត្វល្អិត ដូចជា ឃ្មុំ និងបណ្ដេញសត្វចង្រៃផង
- ប្រើគំរបគ្របគល់ដំណាំទាំងរដូវប្រាំង និងរដូវវស្សា
- ប្រើជីធម្មជាតិ ដូចជា កំប៉ុស្ដ លាមកសត្វពុកផុយ និងជីដែលនៅស្រទាប់ដីផ្នែកខាងលើ ដាក់នៅពេលដាំ និងដាក់បំប៉ន
- នៅរដូវប្រាំងផ្ដល់ទឹកឱ្យបានគ្រប់គ្រាន់ ជាពិសេស នៅពេលប៉េងប៉ោះចេញផ្កា
- ប្រើជ្រលង់ដោតនៅពេលប៉េងប៉ោះមានអាយុ ២០ ថ្ងៃ ក្រោយពីដាំ
- ធ្វើការថែទាំដាក់ជីរហូតដល់ប៉េងប៉ោះមានអាយុ ៣-៤ ខែ ដើម្បីឱ្យផ្លែមានបន្តរហូត

## ៤.៥. បច្ចេកទេសដាំត្រប់របស់កសិករ ធុយ ថុន (ដោយ : ឡាង សេងហ៊ាង)

ដំណាំត្រប់ ជាដំណាំដែលកសិករយើងនិយមដាំនៅដើមរដូវប្រាំង(ពីខែធ្នូ ដល់ខែមេសា) ។ កសិករនៅតាមជួរមាត់ទន្លេមានការនិយមដាំ ព្រោះវាជាដំណាំមានការលូតលាស់ល្អលើដីល្បប់មានជីជាតិ ។ ចំពោះតំបន់ដែលជា បភេទដីល្បាយខ្សាច់ មិនសូវមានគេដាំដុះទេ ។

ដើម្បីផ្តល់ជាគំនិតដល់កសិករ ដែលមានបំណងចង់ដាំដំណាំត្រប់ យើងសូមលើកយកបទពិសោធន៍របស់ កសិករ ធុយ ថុន រស់នៅភូមិក្រសាំង ឃុំជ្រាវ ខេត្តសៀមរាប មកបង្ហាញជូនដូចខាងក្រោម :



**ក- ការរៀបចំដី** : ជាទំលាប់ គាត់តែងតែធ្វើដី ២ ដង ដោយមានការភ្ជួរ និងរាស់ផង។ ការធ្វើដីនេះគឺ សំខាន់ គាត់ភ្ជួរឱ្យជ្រៅ និងរើសស្មៅឱ្យអស់។ ដោយដីជាប្រភេទដីល្បាយខ្សាច់ ហេតុនេះដីដែលភ្ជួរហើយរាងម៉ដ្ឋបន្តិច ។

**ខ- ការបណ្តុះកូន** : គ្រាប់ពូជគាត់បានសំរាំងទុកដោយខ្លួនឯង ។ គាត់បានយកគ្រាប់ពូជទៅបាចនៅលើថ្នាលដែលបានរៀបចំរួចជាស្រេចហើយ ។ ដីលើថ្នាលមានលាយជីដំបូក និងលាមកគោដើម្បី បង្កើនជីជាតិដី និងអាចឱ្យដីរក្សាទឹកបានល្អ។ គ្រាប់ត្រប់*ត្រូវបាចឱ្យស្តើងៗ*នៅលើរង និង*គ្របចំបើងផង*ដែរ ដើម្បីធានាឱ្យកូនដំណាំដុះមកថ្លោស ។

ក្រោយពីសាបហើយ គាត់ថែទាំកូនត្រប់ ដោយស្រោចទឹករាល់ថ្ងៃ (១ ថ្ងៃ ២ ដង) ហើយមានការបំប៉នជីទឹក (ជាប្រភេទជីមានត្រាំទឹកនោម លាមកគោស្រស់ និងរុក្ខជាតិផ្សេងៗ) ២ ដង ។ បន្ទាប់ពីសាបបានអាយុ ៣០ ថ្ងៃ ទើបគាត់ដកកូនយកទៅដាំ ។

**គ- ការដាំ** : គាត់ដាំរបៀបជារង ដោយធ្វើរងរាបស្មើ ។ នៅក្នុងមួយរងគាត់ដាំ ២ ជួរ ដោយចន្លោះពីគុម្ពមួយទៅគុម្ពមួយមានប្រវែង ៦ តឹក (*៦ តឹក បួនជ្រុងស្មើ* ។ នៅតាមគុម្ពកូនដំណាំនិមួយៗមានជីកជារណ្តៅ ។ នៅក្នុងរណ្តៅនិមួយៗ គាត់ដាក់ជីប្រមាណមួយក្បង់ ឬកណ្តាប់ដៃ ។ ប្រភេទជីដែលប្រើមានលាមកគោ លាយអាចម៍ ប្រចៀវ និងជីកែង.កែង.កែង (៤-៥ គ្រាប់) ។ ជីគីមី កែង.កែង.កែង នេះគាត់ប្រើអស់ ៤ គីឡូក្រាម ចំពោះដី មានទំហំ ២៥០ ម៉ែត្រការ៉េ ក្នុងដំណាក់ កាលទ្រាប់បាត ។



### ឃ- ការថែទាំ

ការពូនគល់ និងការប្រើជីលាមកសត្វ

**បន្ថែម :** ក្រោយពីដាំបាន ៣០ ថ្ងៃ *គាត់ចាប់ផ្តើមធ្វើស្មៅ និងជ្រុំដីតាម រងដើម្បីឱ្យដីធូរ និងមានខ្យល់ចេញ ចូលផង ។*

**ការកាយដីពូនគល់ដើមកូនត្រប់**



**ការកាយដីឱ្យខូងកណ្តាលដើម្បីរក្សាទឹកឱ្យដក់នៅកណ្តាលរង**

**ការស្រោចទឹក និងប្រើជីបំប៉ន :**

ដោយដីជាដីល្បាយខ្សាច់ វាទាមទារឱ្យមានការស្រោចទឹកជាប្រចាំ ក្នុងរយៈពេលមួយថ្ងៃស្រោចម្តង ។ *តែនៅពេលមានគំរបលើរង គាត់អាចធ្វើការស្រោចទឹក ២ ថ្ងៃម្តងក៏បាន ។*



**ការគ្របចំបើងនៅលើរងដំណាំត្រប់**

ក្រោយពីពូនរង គាត់បានបូមបង្ហូរទឹកចូលតាមចន្លោះរង២ ទៅ ៣ ថ្ងៃម្តង។ រយៈពេល ៥ ទៅ ៧ ថ្ងៃម្តង រហូតដល់ពេលប្រមូលផលចុងក្រោយ ។ ជាពិសេសគាត់ស្រោចទឹកច្រើន ពេលវាចេញផ្កា ឬពេលប្រមូលផលហើយមួយសា។ ។

### ង- ការប្រមូលផល :

ក្រោយពីដាំបានប្រហែល ២ ខែ ត្រប់អាចធ្វើការប្រមូលផលបាន ដោយបេះក្នុងរយៈពេល ៣ ទៅ ៥ ថ្ងៃម្តង ។ ចំពោះផ្ទៃដី ២៥០ ម៉ែត្រការ៉េ គាត់អាចប្រមូលផលបានពី ៣ ទៅ ៤ ផ្លូន (១២០-១៦០ ផ្លែ) អាស្រ័យតាមអាយុកាលរបស់ដំណាំ ។ គាត់អាចប្រមូលផលបានក្នុងរយៈពេល ២ ខែ តែវាអាស្រ័យដោយការថែទាំ និង ប្រើជី ជាពិសេសជីធម្មជាតិ ។

## ៤.៦. បទពិសោធន៍ដាំឆៃថាវ (ដោយ : ពាន សុខា)



លោកពូ **ថុង គឹមឡេង** ជាកសិករសរស់នៅភូមិស្វាយតានី ឃុំព្រៃកគយ ស្រុកស្អាង ខេត្តកណ្ដាល ។ គាត់មានបទពិសោធន៍ដាំដុះបន្លែជាច្រើនឆ្នាំមកហើយ ជាពិសេសដំណាំឆៃថាវ ។ ក្នុងការដាំដុះនេះ លោកពូមិនបានប្រើប្រាស់ថ្នាំពុល គឺមិច្រើនដូចកសិករជិតខាងគាត់ទេ ចំណែកទិន្នផលទទួល បានខ្ពស់ដូចគេដែរ ។ បទពិសោធន៍របស់គាត់បង្ហាញជូនដូចខាងក្រោម :

### ☆ របៀបសាប និងថែទាំ




**ការរៀបចំរងដាំឆៃថាវ**

នៅលើរង គាត់សាបគ្រាប់នៅក្នុងចង្អូរតូចៗរួចគ្របចំបើងពីលើរង ហើយស្រោចទឹកជារៀងរាល់ថ្ងៃ(១ថ្ងៃស្រោច២ដង) ។ ក្រោយពីសាបបាន ១០ ថ្ងៃគាត់ធ្វើការ *ដករំលោះកូនចេញខ្លះ* ដោយទុក៥ដើមក្នុងមួយចង្អូរគឺ *ទុកតែដើមណាដែលរឹងមាំល្អ ប៉ុណ្ណោះនិងចន្លោះពីដើមមួយទៅមួយ១តឹកកន្លះ។*

ការស្រោចទឹកត្រូវធ្វើជាប្រចាំ ១ ថ្ងៃ ២ ដង រហូតដល់ឆៃថាវចុះមើម និងមើមធំ ។ រយៈពេល ចាប់ពីសាបដល់ប្រមូលផលគឺ ១ ខែកន្លះ ។

### ☆ ការការពារទប់ទល់នឹងការបំផ្លាញរបស់សត្វល្អិត

ដំណាំឆៃថាវ ច្រើនតែជួបប្រទះសត្វល្អិតបំផ្លាញ (ស៊ីស្លឹក) ដូចជា សត្វទុយគា (សត្វត្រចៀកគូ) ដង្កូវ យោលទោង ។ល។ នៅពេលជួបប្រទះការបំផ្លាញពីសំណាក់សត្វទាំងនេះ គាត់បានប្រើថ្នាំផ្សំពីរុក្ខជាតិ ដូចជា ម្ទេសទុំ ផ្លែប៉ិគក់ សំបកដើមឡេប ។



**វិធីផ្សំ :**

| | | |
|---|---|---|
| | ម្ទេសទុំ : | ១ គីឡូក្រាម |
| | ផ្លែប៉ិគក់ : | ១ គីឡូក្រាម |
| | សំបកដើមឡេប : | ១ គីឡូក្រាម |



ធាតុផ្សំទាំងនេះបុកចូលគ្នាត្រាំក្នុងទឹក ២៥ លីត្រ រក្សាទុកក្នុងរយៈពេល ១ អាទិត្យ ទើបយកទៅបាញ់លើដំណាំ ។

ការបាញ់ គាត់ប្រើធុងស្ទប់ដែលមានចំណុះ១៥ លីត្រ(ទឹក) លាយជាមួយទឹកថ្នាំ២ កូនកែវស្រា បាញ់នៅពេលល្ងាច(ព្រលប់) ។ ក្រោយពីបាញ់ហើយ ១០ នាទី គាត់ស្រោចទឹកលាងថែមទៀត ។ ការបាញ់ថ្នាំប្រព្រឹត្តទៅ ៣ ទៅ ៤ ថ្ងៃម្តង រហូតដល់ប្រមូលផល ។

**ចំណាប់អារម្មណ៍របស់កសិករ** : ក្រោយពីការដាំដុះបន្លែអស់រយៈពេលច្រើនឆ្នាំមកហើយ លោកពូមានចំណាប់អារម្មណ៍ដូចតទៅ :

- ក្នុងការដាំបន្លែ បើសិនជាយើងចង់បានទិន្នផលខ្ពស់ ត្រូវយកចិត្តទុកដាក់លើការថែទាំឱ្យបានទៀងទាត់ ដូចជា *បោចស្មៅ ថែមដី ស្រោចទឹក បាញ់ថ្នាំ ផ្សំពីរុក្ខជាតិ ដើម្បីការពារសត្វល្អិត* ។ល។ បើគ្រប់គ្រងបញ្ហានេះមិនបានទេ យើងមិនអាចទទួលផលបានទេ ។
- ការដាំ*ត្រូវផ្លាស់មុខបន្លែ* កុំដាំបន្លែដដែលៗ លើដីដដែល ព្រោះវានាំឱ្យកើតសត្វល្អិតកាន់តែច្រើនប្រើដីច្រើន និងមិនសូវបានទទួលផលទៀតផង ។
- ចំណែកកូនឆៃថាវត្រូវរក្សាទុកកូនដែលរឹងមាំ ថ្លោសល្អ
- ចំពោះដំណាំឆៃថាវ បើយើងទុកយូរហួសពេក (៣ ទៅ ៥ ថ្ងៃ) មិនដក នាំឱ្យឆៃថាវក្លាយទៅជាស្ពោត ដែលធ្វើឱ្យអន់គុណភាព ។
- ត្រូវដាំដំណាំដែលធ្វើឱ្យយើងអាចកែច្នៃទុកលក់ទៀតបាន និងមានរយៈពេលលូតលាស់ខ្លីដូចជា ត្រសក់ ឆៃថាវ ស្ពៃជ្រក់ ។ល។ ព្រោះការប្រកបរបរដាំបន្លែលក់ វាមិនទៀងទាត់ វាអាចខាត និងចំណេញ ទោះបីជាយើងក្តាប់បាន តាមរដូវនៃតំរូវការទីផ្សារយ៉ាងណាក៏ដោយ ។ ដូច្នេះ បើតំលៃនៅ ទីផ្សារថោកពេក យើងត្រូវកែច្នៃវាធ្វើជាផលិត ផលមួយផ្សេងទៀត ដូចជា ធ្វើឆៃប៉ូវ ជ្រក់ត្រសក់ ជ្រក់ស្ពៃ អាចលក់បានតំលៃថ្លៃជាងក៏មាន ។

## ៤.៧. ននោងមួយគុម្ពផ្តល់ផល ១៤០ ផ្លែ (ដោយ : ស៊ុម សាមឿន)

លោក **សឿ សេក** ជាកសិករសនៅភូមិពណ្ណរាយ ឃុំចើងដើង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ គាត់បានសហការជាមួយអង្គការអាដ្រា (ADRA) បង្កើតបានសួនដំណាំចំរុះមួយលើផ្ទៃដី ៣២០ ម៉ែត្រការ៉េ ។ នៅក្នុង សួនគាត់មានដាំបន្លែ ដូចជា សណ្តែកកួរ ត្រប់ ននោង ត្រសក់ និង គ្រឿងទេសផ្សេងៗ ។ ប៉ុន្តែក្នុងចំណោមដំណាំទាំងនេះ គាត់មានបទពិសោធន៍ល្អជាងគេក្នុងការដាំននោង ។ យើងសូមបង្ហាញបច្ចេកទេសដាំរបស់គាត់ ដូចខាងក្រោម ÷

ក- ការបណ្តុះកូន :

ដំបូង លោកពូចាប់ផ្តើមបណ្តុះកូនជាមុនសិន ។ គាត់រៀបចំថង់ដោយដាក់ដីលាយនឹងដីកំប៉ុស្ត រួចយកគ្រាប់ននោងចំនួន ២ ទៅ ៣ គ្រាប់កប់ ហើយស្រោចទឹកចំនួន ២ ដង ក្នុងមួយថ្ងៃ ។ ពេលគ្រាប់ដុះបានរយៈពេល ៧ ថ្ងៃ គាត់ដកដើមដែលអន់ចេញ *ដោយរក្សាទុកតែដើមរឹងមាំមួយដើម* ហើយទុករហូតបានអាយុ ១៥ ថ្ងៃ ទើបយកទៅដាំក្នុងរណ្តៅ ។

ខ- ការរៀបចំរណ្តៅ :

លោកពូបានដាំននោងលើផ្ទៃដី ៧០ ម៉ែត្រការ៉េ ដែលអាចរៀបចំជារណ្តៅបានចំនួន ៦ ។ រណ្តៅនិមួយៗមានទំហំ ១ ម៉ែត្របួនជ្រុង និងជំរៅកន្លះម៉ែត្រ ។ ក្រោយពីជីកហើយ គាត់ហាលរណ្តៅទុកចោលចំនួន ៧ ថ្ងៃ ទើប ចាប់ផ្តើមដាក់ជីលាមកគោ ៥ បង្គី ក្នុងមួយរណ្តៅដោយលាយជាមួយដីក្រមៅ ស្រទាប់លើ ។

គ- របៀបដាំ :

ក្នុងការដាំ គាត់បានជ្រើសរើសនៅពេលល្ងាចត្រជាក់ ដើម្បីកុំឱ្យស្រពោនដើម ។ ក្នុងមួយរណ្តៅគាត់ដាំ ននោងចំនួន ២ ទៅ ៣ ដើម ដោយកប់ដើមត្រឹមដីដែលដាក់ក្នុងកន្ទោង ឬថង់ ប៉ុណ្ណោះ ។

ឃ- ការរៀបចំទ្រើង :

នៅពេលដែលកូនននោងបោះដៃបាន ១ ម៉ែត្រកន្លះ *គាត់ពត់ដើមមួយជុំរួចកប់ដីដែលមានជីជាតិមួយបង្គី ពីលើ ដោយទុកដៃឱ្យវារឡើងទ្រើង* ប្រវែងពី ៣ ទៅ ៥ តឹក ។ គាត់បានធ្វើទ្រើង ពីឫស្សី ឬឈើកំពស់ ១ ម៉ែត្រកន្លះ ដើម្បីឱ្យវារឡើង ។

ង- ការថែទាំ :

ក្នុងការ *ថែទាំនេះ* *លោកពូបានបោចស្មៅជុំវិញរណ្ដៅ ពូនគល់ ជ្រុំដីកំប៉ុស្តលាយ ចំនួន ១ បង្គីកន្លះ ដាក់ក្នុងមួយរណ្ដៅ នៅពេលដែលនទោងចាប់ ផ្ដើមចេញផ្កា។*

ចំពោះសត្វល្អិតដែលតែងតែបំផ្លាញ *មានស្រឹង និង ដង្កូវផែនដី* ។ សត្វស្រឹងតែងតែទិចផ្លែខ្ចីៗ ។ ដើម្បីការពារពួកសត្វទាំងនេះ គាត់បានប្រើ *ភ្លើងគប់បង្ហុយរៀងរាល់ថ្ងៃ* គឺធ្វើនៅពេលថ្ងៃត្រង់ បន្ទាប់មក *បាញ់ទឹកលើទ្រើង*។ គាត់បានអះអាងថាការធ្វើរបៀបនេះ គឺអាចកាត់បន្ថយការបំផ្លាញបាន ។



**របៀបពំនូដើមនទោងកប់ដីមួយជុំ**
**(ដើមនទោងត្រូវបានពូនដីកប់ដីលើ)**

ច- ការប្រមូលផល :

យើងអាចចាប់ផ្ដើមទទួលផលនទោងស្រាលនេះបានច្រើនពីអាយុ៤៥ ថ្ងៃ រហូតដល់អាយុ៩០ ថ្ងៃ។ ចាប់ពីអាយុ៩០ ថ្ងៃឡើងទៅ ទិន្នផលចាប់ផ្ដើមថយចុះ ។ ក្នុងមួយខួបជីវិតរបស់វា គាត់អាច *ប្រមូលផលបាន ១៨០ ផ្លែ ក្នុង ១ គុម្ព* ។ មានន័យថា គាត់អាចប្រមូលបាន ១០៨០ ផ្លែ ចំពោះនទោង ចំនួន ៦ គុម្ព ។

សរុបមក បទពិសោធន៍របស់លោកពូគឺ :

- ☞ កាប់រណ្ដៅហាលចោលមួយអាទិត្យ
- ☞ ប្រើជីកំប៉ុស្ត និងលាមកសត្វដាក់ក្នុងរណ្ដៅ និងជ្រុំគល់
- ☞ បណ្ដុះកូននទោង២ ទៅ ៣ ដើមក្នុងមួយថង់ ហើយទុកតែកូនដុះល្អតែមួយដើមសំរាប់យកទៅដាំ។
- ☞ នៅពេលនទោងដុះបាន១ ម៉ែត្រទៅ១ ម៉ែត្រកន្លះ ត្រូវព័ទ្ធដើមកប់ដី ១ ជុំ ដោយយកដីមានជីជាតិមកកប់ពីលើ ទើបឱ្យវារឡើងទ្រើង
- ☞ ពេលមានសត្វល្អិតបំផ្លាញ គាត់ប្រើភ្លើងគប់បង្ហុយ ។

## ៤.៨. របៀបទុកពូជប៉េងប៉ោះ (ដោយ : ពាន សុខា និង ហ៊ីង ស្រីមុំ)

ក្រៅពីដាំប៉េងប៉ោះបានផលល្អ លោកពូ **ហែម សារឿន** ក៏មានបទពិសោធន៍ទុកពូជប៉េងប៉ោះប្លែកពីកសិករដទៃទៀត នៅក្នុងភូមិរបស់គាត់ដែរ ។ ខាងក្រោមនេះជាបទពិសោធន៍ទុកពូជប៉េងប៉ោះរបស់គាត់ :

- គាត់ជ្រើសរើសយកផ្លែប៉េងប៉ោះទុំល្មម មិនខ្ចីពេក មិនជោរពេកពុះទទឹង ដាក់ក្នុងចានច្របាច់ឱ្យចេញគ្រាប់ ។



*ការពុះ និងច្របាច់គ្រាប់ប៉េងប៉ោះដាក់ក្នុងចាន*

- ក្រោយពីច្របាច់គ្រាប់ចេញហើយ យកទៅត្រាំទឹកធម្មតាចំនួន ១២ ម៉ោង ។ បន្ទាប់មកលាងទឹកច្របាច់យកស្រោមគ្រាប់ចេញរហូតទាល់តែអស់រំអិល ។



*ត្រាំគ្រាប់ប៉េងប៉ោះក្នុងរយៈពេល ១២ ម៉ោង*

- ក្រោយពីលាងសំអាតហើយ យកទៅហាលថ្ងៃ ( ហាលថ្ងៃក្តៅ ) ក្នុងរយៈពេលពី ៥ ថ្ងៃ ទៅ ៧ ថ្ងៃ ទើបឈប់ហាល ។



*ការហាលគ្រាប់ប៉េងប៉ោះក្រោមពន្លឺថ្ងៃ*

- បន្ទាប់ពីហាលថ្ងៃចំនួន ១ ខែកន្លះមក គាត់យកទៅហាលទឹកសន្សើមអស់ រយៈពេល ៤ ទៅ ៥ យប់បន្ថែមទៀត ដើម្បីឱ្យគ្រាប់ស្រួយ ។



*ការហាលគ្រាប់ប៉េងប៉ោះនៅពេលយប់ឱ្យត្រូវសន្សើម*

- បន្ទាប់មក យកគ្រាប់ដាក់ក្នុងចាន ឬចង្អេរអុំ ហើយយកដៃរូសឱ្យអស់សំបក គ្រាប់នៅសល់តែសាច់គ្រាប់សុទ្ធ រួចយកទៅរោយខ្យល់ឱ្យអស់សំបក ទើបច្រកទុកក្នុងដប ។




*អុំ-រែងឱ្យស្អាតមុនច្រកទុកក្នុងដប*

តាមបទពិសោធន៍របស់គាត់កន្លងមកឃើញថា ការទុកពូជប៉េងប៉ោះរបៀបនេះទទួលបានលទ្ធផលល្អ គឺ គ្រាប់ដុះបានច្រើន ( ៩៩ ភាគ រយ ) ផ្លែច្រើន គ្រាប់ពូជទុកបានយូរខែឆ្នាំ ។

## ៤.៩. បច្ចេកទេសដាំខ្ទឹមស្លឹកលើរាន (ដោយ : ឡាង សេងហ៊ង)

កសិកររស់នៅភូមិដំណាក់ពពូល ឃុំកំពង់ឆ្នាំង ស្រុកកំពង់ឆ្នាំង ច្រើននិយមដាំខ្ទឹមស្លឹក ដែលអ្នកស្រុកនោះ ឱ្យឈ្មោះថាខ្ទឹមក្រហម ឬខ្ទឹមគុយទាវ (ចំពោះអ្នកស្រុកនៅមាត់ទន្លេ គេហៅខ្ទឹមខ្យល់) ។ ខ្ទឹមនេះមានស្លឹកធំវែង និងមើមតូចរាងស្ដួច មិនប៉ោង ។ ខ្ទឹមនេះគេហូបបង់សំឡ ឬឆាធម្មតា ដោយប្រើទាំងគល់ទាំងស្លឹក ដូចពួកខ្ទឹមស្លឹក ដែលដាំនៅតាមដងទន្លេដែរ ។




លោកអ៊ុំ **ស៊ូ យ៉ាន** ដែលរស់នៅក្នុងភូមិ ឃុំខាងលើ គាត់មានបទពិសោធន៍ដាំប្រភេទពូជ ខ្ទឹមនេះជាច្រើនឆ្នាំមកហើយ ។ រីឯបទពិសោធន៍ដាំរបស់ គាត់មានដូចខាងក្រោម :

### ✪ របៀបរៀបចំរានដាំ

គាត់រៀបរានសំរាប់ដាំ ដោយយកឡាំងឈើធ្វើជារានដែលមានក្រាលឫស្សីពីក្នុង ។ ទទឹងរានមានប្រវែង១ម៉ែត្រទៅ ១ ម៉ែត្រកន្លះ កំពស់ ២ តឹក និងបណ្ដោយអាស្រ័យទៅតាមចិត្តយើងចង់បាន ។ នៅពេលដែលរៀបចំរានហើយ គេត្រូវរកកំណល់កល់ ជើងរានឱ្យផុតពីដី ។ រួចយកស្មៅមកក្រាលនៅបាតរាន(ផ្ទៃរ) ។ បន្ទាប់មកទើបយកដីដែលមានជីជាតិ (យកល្អមានលាយដីដំបូក) មកចាក់ពីលើស្មៅឱ្យបានកំរាស់ពី ១ តឹកទៅ ១ តឹកកន្លះ ដោយពង្រាបដីឱ្យស្មើ ហើយរើសយកដុំក្រួស និងស្មៅផ្សេង១ចេញ ។ នៅពេលរៀបចំដីហើយ គាត់ស្រោចទឹកលើរានឱ្យសើមតិច១ រួចដាំតែម្ដង ។



### ✪ របៀបដាំ

គាត់បំបែកកូនពីរានផ្សេងទៀត ដែលគាត់បានដាំយកមកដាំនៅលើរានដែលបានរៀបចំស្រេច ដោយ ស្ទូងចន្លោះគុម្ពឃ្លាតពីគ្នា ១ តឹកបួនជ្រុង ។

### ✪ ការថែទាំ និងដាក់ជី

ក្រោយពីស្ទូងហើយ គាត់ស្រោចទឹក ១ ថ្ងៃ ម្ដង (នៅរដូវប្រាំង) ។ តែនៅរដូវវស្សាគាត់ស្រោចពី ២

ទៅ ៣ ថ្ងៃម្តង ។ ដើម្បីឱ្យខ្ទឹមដុះលូតលាស់បានល្អ គាត់បានដាក់ជីបំប៉ន ដោយមានទឹកនោមមនុស្ស និងជីអ៊ុយរ៉េ ស្រោចក្នុងរយៈពេលមួយសប្តាហ៍ម្តង ។ ជីដែលស្រោចមានលាយទឹកនោម ១ វែក ជីអ៊ុយរ៉េ ២០ ទៅ ៣០ គ្រាប់ ជាមួយនឹងទឹក ១៥ លីត្រ ។ នៅពេលដែលខ្ទឹមដុះលូតលាស់ល្អ គាត់ចាប់បំបែកកូន យកទៅលក់ ។ ការបំបែកនេះធ្វើឡើងរៀងរាល់ ១៥ ថ្ងៃម្តង ។ ក្នុងពេលបំបែក គេត្រូវទុកខ្ទឹម ២ ទៅ ៣ ដើម ក្នុងមួយគុម្ព ដើម្បី ឱ្យវាបែកកូនតទៅទៀត ។



ការដកបំបែកកូន

រាល់ពេលធ្វើការដកបំបែកខ្ទឹមហើយត្រូវជ្រុំជី និងដាក់ជីលាមកសត្វ ឬលាយជាមួយផេះអង្កាម ឬផេះអុសចង្រ្កានថែមទៀត ដើម្បីឱ្យខ្ទឹមបន្តការលូតលាស់ ។ ក្នុងផ្ទៃដី ២ ម៉ែត្រការ៉េ គាត់អាចបំបែកកូនបានពី១ ទៅ២ គីឡូក្រាម ក្នុងមួយសា។ ការបំបែកនេះ គឺធ្វើឡើងរហូតដល់រយៈពេល៥ ទៅ ៦ ខែទើបឈប់ ។ គាត់ក៏បានបញ្ជាក់ផងដែរថា ដីដែលយើងបានដាំខ្ទឹមមួយសាហើយគឺត្រូវតែដូរចេញដាក់ដីថ្មី ។ ធ្វើយ៉ាងនេះ ទើបខ្ទឹមដុះលូតលាស់ល្អ និងមិនមានជំងឺ ឬសត្វល្អិតបំផ្លាញ ។

សរុបមក ដើម្បីដាំខ្ទឹមលើរានឱ្យបានល្អ យើងត្រូវអនុវត្តន៍នូវចំណុចមួយចំនួនដូចខាងក្រោម :

- រៀបចំធ្វើរានដោយប្រើសំបកឡាំង និងឫស្សី
- រៀបចំដាក់ជីក្រាលលើរាន ដោយប្រើស្មៅក្រាលនៅបាត និងដីដំបូក ឬដីមានជីជាតិក្រាលពីលើស្មៅ
- ស្រោចទឹកលើរានឱ្យជោគ ទើបយកកូនខ្ទឹមមកដាំដោយទុកចន្លោះគុម្ព ១ តឹក បួនជ្រុង
- ថែទាំដោយដកស្មៅ ស្រោចទឹកនិងដាក់ជីបំប៉ន
- នៅពេលខ្ទឹមលូតលាស់ ត្រូវដកបំបែកកូនដោយទុកតែ ២-៣ ដើមក្នុង ១ គុម្ព ដើម្បីឱ្យវាដុះតទៅទៀត
- រាល់ពេកដកបំបែកខ្ទឹម ត្រូវជ្រុំជីដាក់ជីលាមកសត្វ និងជីអង្កាមបន្ថែម ហើយស្រោចទឹកដើម្បីឱ្យខ្ទឹមដុះលូតលាស់បន្ត ។

## ៩.១០. បទពិសោធន៍ដាំឃ្លោកនៅរដូវប្រាំង ( ដោយ : យី គីមថាន)

ឃ្លោកជាដំណាំដែលកសិករនិយមដាំបំផុតនៅតាមសួនគ្រួសារ ព្រោះវាមានលក្ខណៈងាយស្រួលដាំ ។ ប៉ុន្តែបើយើងមានបច្ចេកទេសដាំបានល្អ ធ្វើឱ្យយើងទទួលបានទិន្នផលកាន់តែច្រើន និងអាចសន្សំសំចៃទឹកបានទៀតផង ។ ខាងក្រោមនេះជាបទពិសោធន៍របស់កសិករ **កែន កំសាន្ត** រស់នៅភូមិទ្រា ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង គាត់ចេះពីរបៀបដាំឃ្លោកនៅរដូវប្រាំងទទួលបានទិន្នផលខ្ពស់ ។

**ការរៀបចំដី :**

- ជាដំបូងគាត់ជីករណ្ដៅដែលមានទទឹងប្រវែងកន្លះម៉ែត្រ បណ្ដោយ២ ម៉ែត្រ និងជំរៅកន្លះម៉ែត្រ
- ត្រូវហាលរណ្ដៅនោះរយៈពេល ៣ ថ្ងៃ ដើម្បីឱ្យវាស្ងួតដី
- យកដើមចេកចំនួន ២ ដើមមកកាត់ជាកំណាត់ៗ ដើម្បីងាយស្រួលដាក់ក្នុងរណ្ដៅ ។ បន្ទាប់ពីយកដើមចេកកាត់ជាកំណាត់ៗ ទៅតំរៀបក្នុងរណ្ដៅរួចមកត្រូវលុបដីឱ្យពេញមាត់រណ្ដៅ
- យកជីកំប៉ុស្ដទៅច្របល់ជាមួយដីនៅមាត់រណ្ដៅ តែប្រសិនបើគ្មាន អាចយកដីណាដែលមានជីជាតិច្របល់ជាមួយអាចម៍មាន់ ទា ឬអាចម៍គោ ហើយយកទៅដាក់លើមាត់រណ្ដៅ
- ស្រោចទឹកលើរណ្ដៅឱ្យជោគ ហើយយកគ្រាប់ឃ្លោកមកដាំ ដោយមួយរណ្ដៅដាក់ ១ ទៅ ២ គ្រាប់ និង ចន្លោះពីគុម្ពមួយទៅគុម្ពមួយប្រវែង ២ តឹក ( ដាំតែ ១ ជួរទេ ) ។

**ការថែទាំ :**

ត្រូវស្រោចទឹករៀងរាល់ថ្ងៃលុះត្រាតែឃ្លោកដុះបានប្រវែងកន្លះម៉ែត្រ តែបន្ទាប់ពីនោះគឺយើងស្រោច ២ ដងក្នុងមួយអាទិត្យ ព្រោះឫសវាចាក់ដល់ដើមចេកហើយដើមចេកវាមានជាតិទឹកធ្វើឱ្យឫសអាចស្រូបបាន។ ក្រោយពីគ្រាប់ឃ្លោកបានដុះ ហើយត្រូវដករំលោះកូនចេញខ្លះ ដោយទុកតែមួយដើមក្នុងមួយគុម្ព។

**ការធ្វើទ្រើង :**

នៅពេលឃ្លោកដុះលូតលាស់បានកំពស់កន្លះម៉ែត្រ គាត់ចាប់ផ្ដើមធ្វើទ្រើងឱ្យវា វារឡើង។ ការធ្វើទ្រើងនោះ គឺត្រូវធ្វើឱ្យមានលក្ខណៈជំរាលឡើងទៅលើ ដែលមានទទឹង ៣ ម៉ែត្រ និងបណ្ដោយ ៥ ម៉ែត្រ។ លុះដល់ឃ្លោកលូតលាស់បានប្រវែង ១ ម៉ែត្រ គាត់ចាប់យករំពាត់ឆ្មារទៅវ៉ាត់ទងផ្នែកខាងត្រួយឱ្យដាច់ ដើម្បីឱ្យវាបែក ខ្នែងច្រើន និងឆាប់មានផ្កាផ្លែ ។




**ការប្រមូលផល** ៖ ក្នុងផ្ទៃដីដែល គាត់បានរៀបរាប់ខាងលើនេះ គាត់អាចទទួលបានឃ្លោកជាង ១០០ ផ្លែ ។ បេះម្តងបានឃ្លោក ៤ ទៅ ៥ ផ្លែ ហើយបេះបាន ២៥ ដង ក្នុងមួយវដ្តជីវិតរបស់វា ។

ការដាំរបៀបនេះ គឺឃ្លោកអាចទទួលបានជីជាតិគ្រប់គ្រាន់ និងសន្សំសំចៃទឹកទៀតផង ។ នៅពេលឃ្លោកចាប់ផ្តើមដុះវាស្រូបយកជីជាតិពីដីផ្នែកខាងលើដែលយើងបានដាក់ជី ដល់ពេលវាធំ ឫសវាចាក់ទៅដល់ដើមចេកដែលអាចឱ្យវាស្រូបយកជីជាតិបានច្រើន និងមានជាតិគ្រប់គ្រាន់ទៀតផង ដោយសារដើមចេកវាត្រជាក់ ហើយសំបូរជាតិទឹក ។

សរុបមក ដើម្បីដាំឃ្លោកឱ្យបានផ្លែច្រើន យើងត្រូវ :

- ត្រូវជីករណ្តៅឱ្យបានធំ និងជ្រៅ
- ដាក់កំណាត់ដើមចេកនៅបាតរណ្តៅ និងជីលាមកសត្វច្របល់លាយជាមួយដីនៅផ្នែកខាងលើ
- ស្រោចទឹកឱ្យជោគ រួចយកគ្រាប់ឃ្លោកមកដាំក្នុងរណ្តៅ (ដោយក្នុង ១រណ្តៅដាក់ពី ១ ទៅ ២ គ្រាប់)
- នៅពេលឃ្លោកដុះលូតលាស់បានកំពស់កន្លះម៉ែត្រ ត្រូវធ្វើទ្រើងឱ្យវារឡើងទ្រើង ត្រូវធ្វើឱ្យមានលក្ខណៈជំរាល
- នៅពេលឃ្លោកលូតបាន ១ ម៉ែត្រ ត្រូវកាត់ត្រួយចេញឱ្យវាបែកខ្នែងច្រើន និងឆាប់មានផ្លែផ្កា ។

## ៩.១១. បទពិសោធន៍ដាំម្ទេស របស់កសិករ នៅស្រុកអង្គស្នួល ខេត្តកណ្ដាល (ដោយ : សម វិទូ)

**ម្ទេស** ជាប្រភេទដំណាំមួយដែលងាយស្រួលដាំ ។ ប៉ុន្តែ បើសិនជាយើងចេះរៀបចំឱ្យបានល្អ ម្ទេសអាចផ្ដល់ ផលជាទីគាប់ចិត្ត ។ ខាងក្រោមនេះ ជាបទពិសោធន៍នៃការដាំម្ទេស របស់កសិករ **ម៉ី សោម** រស់នៅភូមិត្រពាំង វាំង ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល ។

### ✪ ការរៀបចំដី :

នៅលើផ្ទៃដី ១០ ម៉ែត្របួនជ្រុង (១០ម. ខ ១០ម.) គាត់រៀបចំធ្វើជាសួនរង្វង់ដែលមានអង្កត់ផ្ចិត១ ម៉ែត្រ ចំនួន៦៣ រង្វង់ ។ នៅក្នុងសួនរង្វង់ គាត់ដាក់ស្លឹកឈើងាប់ សំរាម ស្លឹកឈើស្រស់ លាមកគោ ដាក់រហូត ពេញរណ្ដៅ ហើយរោយដីលប់តិចៗ ដើម្បីកុំឱ្យសំរាមប៉ើង ។



**រណ្ដៅសួនរង្វង់ដែលមានដាំម្ទេសនៅមាត់រណ្ដៅ**

### ✪ ការបណ្ដុះកូន :

កូនម្ទេស ត្រូវចាប់ផ្ដើមបណ្ដុះ (បណ្ដុះនៅមាត់រណ្ដៅ) នៅពេលដែលចាប់ផ្ដើមកាប់រង្វង់ ។ នៅពេលដែលជីត្រូវដាក់នៅក្នុងរង្វង់ពេញនោះកូនម្ទេសធំល្មមសំរាប់យកទៅដាំ ។ នៅលើគែមរណ្ដៅរង្វង់ក្រៅពីម្ទេស គាត់បានដាំត្រប់ និងប៉េងប៉ោះ ។

## ✪ ការផែទាំ :

- ពេលម្ទេសនៅតូច វាមិនសូវត្រូវការទឹកប៉ុន្មានទេ ។ ប៉ុន្តែ ត្រូវស្រោចទឹកមួយថ្ងៃម្តង ម្តងមួយប៉ោត ព្រោះនៅលើគែមរង្វង់នោះមានដំណាំផ្សេងទៀត ។ នៅពេលដែលដីនៅក្នុងរណ្តៅរង្វង់ស្រុតចុះត្រូវបន្ថែមស្លឹកឈើស្រស់ ឬលាមកសត្វទៀត ។

- បើមានស្រមោចឡើងត្រូវបាចផេះ ឬប្រើជីកំប៉ុស្តទឹក ដោយយកទឹកមួយប៉ោតដាក់លាយជីកំប៉ុស្តទឹកមួយកំប៉ុង ។

## ✪ ការប្រមូលផល :

ដោយសារការដាំចម្រុះគ្នា ផលដែលបានទទួលមុនគេ គឺប៉េងប៉ោះ បន្ទាប់មកត្រប់ ។ ចំណែកឯម្ទេសផ្តល់ផលក្រោយគេ តែវាផ្តល់ផលបានយូរជាង និងតម្លៃថ្លៃជាងដំណាំពីរទៀត ។ ម្ទេសដែលបេះដំបូងបានចំនួន ២,៥ គ.ក្រ ។ ផលរបស់វាចេះតែកើនឡើងរហូតដល់ ១៥ គ.ក្រ ក្នុងការបេះម្តងៗ ។ ចំណែកឯតំលៃវិញ គឺថោកបំផុត ២០០០ រៀល/គ.ក្រ រហូតដល់ ៨០០០ រៀល/គ.ក្រ ។

*ប្រសិនដីដែលធ្លាប់ដាំម្ទេស ត្រប់ ប៉េងប៉ោះ ហើយនោះ គឺយើងមិនត្រូវ ដាំវាទេ នៅឆ្នាំបន្ទាប់ ។ ទោះបីជា យើងដាំវាក៏មិនអាចផ្តល់ផល ឬផលតិចតួច បំផុតដែលធ្វើឱ្យយើងខាតបង់កំលាំង ។ តែយើងអាចដាំដំណាំមើម ឬ ដំណាំយក ស្លឹកជំនួស ឬពពួកសណ្តែកវិញ ដើម្បីរក្សាជីជាតិដី ។*

សរុបមក ដើម្បីដាំម្ទេសឱ្យបានផលល្អនៅរដូវប្រាំង យើងត្រូវ :

- រៀបចំសួនដែលមានរាងជារង្វង់
- នៅក្នុងរណ្តៅសួនរង្វង់ ត្រូវដាក់ស្លឹកឈើស្រស់-ងាប់ លាមកសត្វឱ្យពេញរណ្តៅ រួចលុបដីតិចៗពីលើ
- យកកូនម្ទេសដាំនៅលើគែមរង្វង់ អាចដាំចំរុះជាមួយប៉េងប៉ោះ ត្រប់ ដើម្បីបានផលច្រើនមុខ
- នៅពេលដីនៅក្នុងរណ្តៅស្រុតចុះ ត្រូវបន្ថែមស្លឹកឈើស្រស់-ស្ងួត ឬលាមកសត្វទៀត និងធ្វើការថែទាំដូចជា ស្រោចទឹក កំចាត់សត្វល្អិត ។ល។

## ៤.១២. បទពិសោធន៍ដាំផ្ទីដូង (យ៉ា ណារិទ្ធិ)



ដើម ស្លឹកផ្ទីដូង

ផ្ទីដូងជាប្រភេទបន្លែស្លឹកដែលមានសារធាតុចិញ្ចឹមជីវិតច្រើន ដូចជាវីតាមីនអាកាល់ស្យូម និងជាតិដែក។ មិនតែប៉ុណ្ណោះ វាជាដំណាំដែលងាយស្រួលដាំមិនសូវចំណាយពេលវេលាច្រើន ដោយសារមូលហេតុនេះហើយទើបលោកពូ **មាន យ៉ាន** ដែលជាកសិកររស់នៅក្នុងភូមិសសី ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្ដាល គាត់ជ្រើសរើសដំណាំផ្ទីដូងមកដាំ ចំណែកបទពិសោធន៍របស់គាត់ បង្ហាញជូនដូចខាងក្រោម :

### ១. របៀបរៀបចំគ្រាប់ពូជដាំ

លោកពូបានជ្រើសរើសគ្រាប់ពូជណាដែលខ្មៅរលោងល្អពីដើមយកទៅហាលក្រោមកំដៅថ្ងៃស្រទន់រយៈពេល ២ ទៅ ៣ ថ្ងៃ ទើបគោះយកគ្រាប់ដាំ ។

### ២. របៀបព្រោះគ្រាប់

ដើម្បីឱ្យគ្រាប់ដុះបានល្អ លោកពូបានធ្វើដីឱ្យម៉ដ្ឋល្អម ដោយហាលទុកចោលរយៈពេល ២ ទៅ ៣ ថ្ងៃ ដើម្បីឱ្យដីឆ្អិនល្អ។ ក្រោយពីរៀបចំរងហើយ គាត់យកគ្រាប់ដែលបានត្រៀមទុកទៅព្រោះលើរងស្តើងៗ បន្ទាប់មកទើប យកលាមកគោក្រៀមម៉ដ្ឋរោយពីលើគ្រាប់បន្តិចៗហើយស្រោចទឹក។ ក្រោយពីសាបបានរយៈពេល ១០ថ្ងៃ កូនផ្ទីអាច ដកយកទៅដាំនៅលើរងបាន ។ មុនដកកូនស្ទូង ត្រូវស្រោចទឹក ១ សាសិន ដើម្បីឱ្យដីផុស ការពារមិនឱ្យដាច់ឫស ។

### ៣. ការរៀបចំរងស្ទូងកូន

ក្នុងការលើករងនេះ លោកពូកាប់ដីបំផុសមិនឱ្យម៉ដ្ឋពេកទេ ព្រោះកាលណាធ្វើដីម៉ដ្ឋពេកនាំឱ្យដីហាប់ក្ដាំង ផ្ទៃកលើគ្មានខ្យល់ចេញចូល នៅពេលដែលយើងស្រោចទឹក ។ រងដាំផ្ទី លោកពូលើកកំពស់ ១ តឹក ទទឹង ៨ តឹក និងបណ្ដោយ ១០ ម៉ែត្រ ។ នៅលើរង គាត់បានប្រើជីលាមកសត្វ និងកំប៉ុស្តចំនួន ៤ ទៅ ៥ បង្គី សំរាប់ទ្រាប់បាត ។

### ៤. ការស្ទូងកូន

លោកពូបានយកកូនផ្ទីដែលមានអាយុ ១០ ថ្ងៃ ក្រោយពីសាបមកស្ទូងនៅលើរង ដោយទុកចន្លោះពីដើមមួយទៅមួយ ១ តឹកកន្លះ និងពីជួរមួយទៅមួយ ១ តឹកកន្លះដែរ ។ ក្រោយពីស្ទូងហើយ គាត់បានយកកំទេចចំបើង គ្របពីលើរង រួចស្រោចទឹកជាប្រចាំ ១ ថ្ងៃម្តង ឬ ២ ដង នៅពេលអាកាសធាតុក្តៅ ។ នៅរដូវវស្សាមិនចាំបាច់ស្រោចទឹកទេ ។

### ៥. ការថែទាំ

ការដាំផ្ទីដូង ពុំសូវចំណាយពេលថែទាំទេ ព្រោះផ្ទីដូងងាយស្រួលក្នុងការដុះលូតលាស់ណាស់ជាពិសេស ការដាក់ជីធម្មជាតិ(លាមកសត្វអាចម៍គោ) ធ្វើឱ្យវាដុះលូតលាស់ល្អ ។ ចំពោះស្មៅ គាត់ធ្វើការដកដោយដៃ តែដំណាំផ្ទីពុំសូវមានស្មៅដុះទេ ព្រោះផ្ទីដុះស្ទុះលឿនជាងស្មៅ គ្របដណ្តប់លើស្មៅ មិនឱ្យស្មៅដុះលូតលាស់បាន ។ ប្រសិនបើមាន គាត់ធ្វើការដកដោយដៃ ។ ជីប៉ប៉ន លោកពូបានដាក់ក្រោយពេលកាត់ប្រមូលផលម្តងៗ គឺចំនួន ៣ បង្គី (ជីកំប៉ុស្ត លាមកសត្វ) ។

ផ្ទីដូងពុំមានការបំផ្លាញពីសត្វល្អិតដូចដំណាំស្ពៃ ទេ ដូច្នេះលោកពូមិនបានប្រើថ្នាំពុលឡើយ ។

### ៦. ការប្រមូលផល

ផ្ទីដូងអាចកាត់ប្រមូលផលបានច្រើនសា។ ការកាត់លើកទី ១ ក្រោយពេលស្ទូងកូនរយៈពេល ១០ ថ្ងៃ ពោលគឺនៅពេលមានខ្នែងពន្លកដុះចេញនៅក្បែរគល់ ។ ការកាត់នៅលើខ្នែងពន្លកប្រហែលពាក់កណ្តាលកន្លះតឹក ។ ឯការប្រមូលផលបន្តបន្ទាប់ គឺធ្វើក្រោយគ្នាមួយសប្តាហ៍ ។




**របៀបកាត់ប្រមូលផលដោយទុកដើមនៅលើខ្នែងពន្លក**

សរុបមក ដើម្បីដាំផ្ទីដូងឱ្យបានផលល្អ ត្រូវយក ចិត្តទុកដាក់ចំណុចមួយចំនួនដូចខាងក្រោម :

☞ រើសយកគ្រាប់ខ្មៅរលោងហាលថ្ងៃស្រទន់ ២ ទៅ ៣ ថ្ងៃ មុនយកទៅសាប

☞ រងសាបគ្រាប់ និងរងស្ទូងកូនមិនត្រូវធ្វើដីឱ្យម៉ដ្ឋ ពេកទេនាំឱ្យដីហាប់ស្រទាប់លើ គ្មានខ្យល់ចេញចូល ( ពេលស្រោចទឹក)

☞ ប្រើជីធម្មជាតិ( កំប៉ុស្ត និងលាមកគោក្រៀម) ទ្រាប់បាត និងបំប៉ន ព្រោះផ្ទីត្រូវការលូតលាស់ល្អលើជីធម្មជាតិ

☞ ស្រោចទឹកមួយថ្ងៃ ១ ឬ ២ ដង នៅរដូវក្តៅ និង ប្រើគំរបចំបើងគ្របគល់ដើម្បីរក្សាសំណើមដី

☞ ថែមជីបំប៉នក្រោយពីកាត់ប្រមូលផល ដើម្បីឱ្យផ្ទីអាចមានលទ្ធភាពដុះលូតលាស់បន្ត

☞ ប្រមូលផលដោយកាត់ដើមនៅលើខ្នែងពន្លក ដើម្បីឱ្យផ្ទីអាចដុះលូតលាស់ ។

## ៤.១៣. បច្ចេកទេសដាំត្រឡាចឱ្យបានផ្លែច្រើន ( ដោយ : ចៅ វុទ្ធី)

អ៊ុំស្រី **ធាស ផុន** អាយុ ៦០ ឆ្នាំ ជាកសិករស់នៅភូមិរលួស ឃុំស្រយ៉ូវ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ មានបទពិសោធន៍ដាំបន្លែទទួលបាននូវទិន្នផលខ្ពស់ជាងអ្នកដែលរស់នៅក្នុងតំបន់របស់គាត់ ពីព្រោះអ៊ុំស្រីមានបទ ពិសោធន៍ដាំដំណាំតាំងពីតូចមកម្ល៉េះ ។ ជាពិសេសនៅក្នុងរបប ប៉ុល ពត គេបានចាត់តាំងឱ្យអ៊ុំស្រីជួយដាំបន្លែសំរាប់ផ្គត់ផ្គង់អ្នកភូមិទៀតផង។ ដូច្នេះ យើងខ្ញុំសូមលើកយកបទពិសោធន៍របស់អ៊ុំស្រី **ធាស ផុន** មកបង្ហាញ ជូនដូចខាងក្រោម :

### ១. របៀបរក្សាទុកគ្រាប់ពូជសំរាប់រដូវក្រោយ

ដើម្បីជ្រើសរើសពូជទុកដាំនៅរដូវបន្ទាប់ទៀត អ៊ុំស្រីបានរើសយកផ្លែណាដែលទុំល្អមកពុះ ហើយខ្វេះយកគ្រាប់របស់វាមកហាលថ្ងៃឱ្យស្ងួត រួចយកស្បៃ ឬក្រណាត់មកចងខ្ចប់ទុកដូចគ្រាប់ពូជដទៃទៀតដែរ ។ គាត់បាន បញ្ជាក់ថា ពេលខ្វេះយកគ្រាប់វាមកហាលថ្ងៃ សូមកុំលាងទឹកឱ្យសោះ ។

### ២. ការរៀបចំរណ្តៅសំរាប់ដាំ

ការរៀបចំរណ្តៅសំរាប់ដាំ ត្រូវជ្រើសរើសយកដីកន្លែងណាដែលខ្ពស់ ដើម្បីការពារកុំឱ្យជាំទឹកនៅរដូវវស្សា( បើដាំនៅខែមេសា ឬឧសភា) បើនៅរដូវប្រាំងអាចដាំនៅកន្លែងដីទាបបាន។ រណ្តៅដែលអ៊ុំស្រីបានជីកមានទំហំ ៥ តឹកបួនជ្រុង និងជំរៅ ៣ តឹក ។ បន្ទាប់ពីជីករួច គាត់បានយកលាមកគោស្ងួតមកច្របល់ជាមួយដី រួចយកទៅដាក់ក្នុងរណ្តៅឱ្យពេញ បន្ទាប់មកយកគ្រាប់មកដាក់ដាំតែម្តង ដោយដាក់ ១០ គ្រាប់ក្នុងមួយរណ្តៅ ។

### ៣. ការថែទាំ

- **ការដករំលោះកូន :** នៅពេលដែលត្រឡាចដុះបានស្លឹក ២ ទៅ ៣ គាត់បានដករំលោះកូនណាដែលអន់ចេញ( កូនត្រឡាចណាដែលមិនសូវរឹងមាំ) ដោយទុកតែកូនធំៗ ៤ ដើមក្នុងមួយរណ្តៅ ។ លុះដល់កូនត្រឡាចរាងធំបន្តិច ស្លឹក ៦ ទៅ ៧ ទើបគាត់ដករំលោះមួយសារទៀត ទុកតែកូនណាដែលរឹងមាំជាងគេ ២ ដើមប៉ុណ្ណោះ ។



កូនត្រឡាចដែល
មានដើមរឹងមាំល្អ



កូនត្រឡាចដែលមាន
ដើមមិនសូវរឹងមាំ

- **ការប្រើប្រាស់ជីបំប៉ន :** នៅពេលជ្រុំគល់ដក រំលោះកូនត្រឡាច អ៊ុំស្រីបានយកលាមកគោស្ងួតមកជ្រុំនៅក្នុងរណ្ដៅក្បែរគល់របស់វា ហើយពូនដីពីលើបន្តិច ។ បន្ទាប់ពីថែមជីលើកទី ១ ហើយ បានរយៈពេល ២០ ថ្ងៃ ក្រោយមកគាត់បានយកលាមកគោស្ងួតមកជ្រុំដាក់ក្បែរគល់ម្ដងទៀត( ការដាក់ជីអនុវត្តដូចលើកទី ១ ដែរ) ។

- **ការស្រោចស្រព :** ការស្រោចស្រពធ្វើឡើងជាប្រចាំ ១ ថ្ងៃពីរដង( ព្រឹក-ល្ងាច) ប៉ុន្តែនៅពេលត្រឡាច មិនទាន់ដុះចេញពន្លក ការស្រោចមិនត្រូវធ្វើឱ្យជោគពេកទេ លុះដល់ត្រឡាចដុះចេញស្លឹក ៣ ទៅ ៤ ទើបចាប់ផ្ដើម ស្រោចឱ្យជោគ តែបើរដូវវស្សាមិនចាំបាច់ស្រោចទេ ។

- **ការរៀបចំទ្រើង :** ការដោតទ្រើងធ្វើឡើង នៅថ្ងៃដែលយើងដាក់ជីលើកទី ១ ( ពេលត្រឡាចមានស្លឹក ៣ ទៅ ៤) យើងដោតចុងឫស្សី ឬកូនឈើជុំវិញរណ្ដៅ ដើម្បីឱ្យដៃត្រឡាច( ទង) ចាប់តោងឡើង ។ នៅពេលដែលដៃត្រឡាចឡើងផុតចុងឫស្សី ឬមែកឈើដែលយើងដោតដំបូងយើងត្រូវធ្វើទ្រើងឱ្យវាម្ដងទៀត ទ្រើងលើកក្រោយនេះធ្វើរបៀបជារាន ។



ការដោតទ្រើងពេលត្រឡាចនៅតូច

- របៀបធ្វើទ្រើងពេលត្រឡាចធំ (រាន)

ចំណែកទ្រើងរបស់អ៊ុំស្រីមានទំហំទទឹង ៤ ម៉ែត្រ បណ្តោយ ៧ ម៉ែត្រ និងកំពស់ប្រហែល ២ ម៉ែត្រ ។ ចំពោះទ្រើងជារាននេះ ធ្វើកាន់តែធំ កាន់ តែល្អ ដើម្បីកុំឱ្យវាក្រាស់ពេក ។

## ៤. ការប្រមូលផល

ជាទូទៅ ចំពោះដំណាំត្រឡាច បន្ទាប់ពីដាំបានរយៈពេលប្រហែលជិត ៣ ខែ យើងអាចបេះប្រមូលផលបាន ។ អ៊ុំស្រីចាប់ប្រមូលផលបន្តបន្ទាប់រហូត ។ បើគិតទៅរយៈពេលតែមួយខែប៉ុណ្ណោះ ក្នុងមួយគុម្ពគាត់បេះត្រឡាចបានចំនួន ១២០ ផ្លែ ។ ក្នុងត្រឡាច ១២០ ផ្លែនេះ គាត់លក់នៅទីផ្សារ ៣០ ផ្លែ ក្នុងមួយផ្លែបានតំលៃ ៥០០៛ និងលក់ក្នុងភូមិ ៦០ ផ្លែ ក្នុងមួយផ្លែបាន ៣០០៛ ហើយទុកសំរាប់បរិភោគក្នុងគ្រួសារ ៣០ ផ្លែ។ បើគិតជាទឹកប្រាក់ទាំងទុកបរិភោគ និងលក់ផង សរុបក្នុងរយៈពេលមួយខែ គាត់អាចរកប្រាក់ចំណូលបាន ៤២០០០៛ ហើយគាត់អាចប្រមូលផលបានរហូតដល់ជិត ២ ខែ ទៀត ។ តែនៅដំណាក់កាលចុងក្រោយ ចំនួននៃផ្លែនឹងមាន ការថយចុះបន្តិច មិនដូចការប្រមូលផលលើកដំបូងទេ ។

សរុបមកបទពិសោធន៏សំខាន់ៗ ក្នុងការដាំ ត្រឡាច មានដូចខាងក្រោម :

☞ ពេលត្រឡាចដុះបានស្លឹក ៣ ទៅ ៤ ត្រូវដក កូនចេញខ្លះ ដោយទុកតែ ៤ ដើមក្នុងមួយរណ្តៅ

☞ លុះដល់ត្រឡាចធំបន្តិច (ស្លឹក ៦ ទៅ ៧) ទើប ដករំលោះមួយសារទៀតជាចុងក្រោយ ដោយទុកតែ ២ ដើមក្នុងមួយរណ្តៅ

☞ ធ្វើទ្រើងឱ្យបានធំ

☞ ការពារកុំឱ្យជាំទឹកនៅក្នុងរណ្តៅដាំ

☞ ថែមជីឱ្យបាន ៣ ទៅ ៤ ដង ក្នុងមួយវដ្តជីវិត ជាពិសេសក្រោយពេលប្រមូលផល ២ ទៅ ៣ សា

☞ ស្រោចទឹកឱ្យបានទៀងទាត់ ២ ដង ក្នុងមួយថ្ងៃ នៅរដូវប្រាំង ។

## ៤.១៤. បទពិសោធន៍ដាំចេកពងមាន់ (ដោយ : សុគន្ធ ពិដា)

**សុខ សុរិទ្ធិ** ជាកសិករសរស់នៅភូមិព្រៃកថ្មី ឃុំព្រៃកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ គាត់មានបទពិសោធន៍ដាំចេកពងមាន់ បានផលច្រើនជាងអ្នកជិតខាងរបស់គាត់ ។ បទពិសោធន៍នេះ យើងខ្ញុំសូមបង្ហាញជូនដូចខាងក្រោម :

### ១. ការរៀបចំដីដាំ

លោកពូដាំចេកពងមាន់នេះ លើផ្ទៃដីចំនួន ២០០០ ម៉ែត្រការ៉េ។ ក្នុងការធ្វើដី គាត់ភ្ជួរចំនួន ២ សារ និងរាស់ ១ សារ។ ភ្ជួរលើកទី ១ ក្រោយពីប្រមូលផលដំណាំចាស់ និងភ្ជួរលើកទី ២ រយៈពេលពី ១០ ទៅ ១៥ ថ្ងៃ ក្រោយពីលើកទី ១ ដើម្បីហាលដីឱ្យស្រស់ទឹកល្អ ទើបរាស់កៀយកស្មៅចេញ និងចាប់កាប់រណ្តៅដាំតែម្តង។ នៅលើផ្ទៃដី ២០០០ ម៉ែត្រការ៉េ នេះគាត់កាប់រណ្តៅបានចំនួន ៥០០ រណ្តៅ។ រណ្តៅនិមួយៗ មានទំហំ ៤ តឹកបួនជ្រុង និង ជំរៅ ២ តឹក និងចន្លោះពីគុម្ពមួយទៅគុម្ពមួយគឺ ២ ម៉ែត្រ។

### ២. ការដាំ


ចំការចេករបស់កសិករ សុខ សុរិទ្ធិ

ក្នុងការដាំ គាត់បានយកគល់ចេកខ្លះ និងកូនចេកខ្លះទៅដាំ ។ បន្ទាប់ពីជីករណ្តៅរួច គាត់បានយកគល់ចេកពុះជា ២ ចំណែក ។ ចំណែកកូនចេកវិញ គាត់យកកូនដែលមានកំពស់ពី ៣-៤ តឹក យកទៅដាំ ។

ចំពោះការដាំដោយគល់ ក្នុង ១ រណ្តៅ គាត់ដាក់ ១ ចំហៀង ដោយកប់គល់ផ្ងារឡើងលើ។ ចំណែកកូនចេក គាត់កប់ក្នុងជំរៅ ១.៥ តឹក គឺពាក់កណ្តាលដើម។

សូមបញ្ជាក់ថា មុនដាក់កូន ឬគល់ដាំ គាត់បានដាក់ជីលាមកសត្វពុកផុយចំនួន ១ បង្គី ក្នុង ១ រណ្តៅ ច្របល់លាយជាមួយដី ទើបដាក់កូនដាំ ។

### ៣. ការថែទាំ

ក្រោយពីកប់គល់ និងដើមដាំហើយគាត់បានយកគំរបស្មៅចំបើង និងស្លឹកឈើងាប់ៗ គ្របគល់រួចស្រោចទឹកឱ្យជោគ ។ រយៈពេល ៣ ថ្ងៃ គាត់ធ្វើការស្រោចទឹកម្តងដើម្បីឱ្យវាឆាប់ដុះ ។

ក្រោយពីដាំបានរយៈពេល ២ ខែ កន្លងមក គាត់បានធ្វើការជ្រុំគល់ ដកស្មៅ និងដាក់ជីបន្ថែម។ ជីដែលគាត់ដាក់មាន ជីលាមកសត្វពុកផុយ។ ជីនេះត្រូវបានជ្រុំដាក់នៅតាមគល់ចេក ព្រមទាំងលុបសំរាមដែលគាត់ដាក់គ្របគល់ច្របល់ចូលក្នុងដីផងដែរ។ ក្រោយពីជ្រុំគល់ដាក់ជីហើយ គាត់ប្រមូលកំទេចសំរាមស្លឹកឈើងាប់ៗ មកគ្របសារជាថ្មី ហើយស្រោចទឹកឱ្យជោគ។ នៅពេលដែលគាត់ពិនិត្យឃើញថា សំរាមដែលគ្របគល់ចេកចង់រលួយ គាត់ធ្វើការជ្រុំកប់បញ្ចូលដី ហើយប្រមូលគំរបថ្មីមកគ្របទៀត ។ គាត់ឧស្សាហ៍ធ្វើដូច្នេះ ដើម្បីបង្កើនជីជាតិដល់ដីរបស់គាត់។

ចំពោះការស្រោចស្រពនៅរដូវប្រាំង គាត់ធ្វើការស្រោចស្រព ១ ថ្ងៃ ពី ១ ទៅ ២ ដង។ រីឯរដូវវស្សា គាត់មិនបានស្រោចទឹកទេ តែផ្ទុយទៅវិញគាត់ដើរមើលមានកន្លែងណាដក់ទឹក គាត់បាចទឹកចេញកុំឱ្យទឹកដក់នៅគល់ចេក ធ្វើឱ្យការដុះលូតលាស់មិនបានល្អ ហើយអាចបណ្តាលឱ្យងាប់កូនចេកដែលទើបដុះពន្លកមកថែមទៀត។ សូមបញ្ជាក់ដែរថា *ក្នុង ១ គុម្ព គាត់ទុកតែ ២ ដើមទេ* ដើម្បីឱ្យផ្លែបានធំល្អ។ កូនដែលដុះចេញមកក្រោយ គាត់គាស់ឱ្យអ្នកជិតខាង ឬយកទៅដាំនៅកន្លែងផ្សេង។ ក្រៅពីនេះ គាត់ឧស្សាហ៍កាប់ធាងស្លឹកដែលដុះសាខាចេញ ដើម្បីឱ្យមានពន្លឺថ្ងៃចូលក្នុងចំការបានគ្រប់គ្រាន់។

### ៤. ការប្រមូលផល

ក្រោយពីដាំបានរយៈពេល ៧ ទៅ ៨ ខែ ចេកមានផ្លែ អាចកាត់បន្ទិលក់បាន ។ ការប្រមូលផលមានចំនួន ២ សារ ដោយសរុបទៅចេកចំនួន ៥០០ គុម្ព គាត់ប្រមូលផលបាន ៨០០ ស្និត។

ក្រៅពីការហូបចុកក្នុងគ្រួសារ គាត់អាចលក់នៅទីផ្សារបានតំលៃ ៥៥០០ រៀលទៅ ៦៥០០ រៀលក្នុង ១ ស្និត។ បើគិត ១ រដូវ គាត់អាចរកចំណូលបានពី ៣ ទៅ ៤ លានរៀល។ តែបើគិតដកតំលៃកំលាំងពលកម្ម និងសំភារៈកំប៉ិកកំប៉ុកខ្លះដូចជាពូជ ។ល។ គាត់អាចនៅសល់ប្រាក់ ២ ទៅ ៣ លានរៀលក្នុង ១ ឆ្នាំ ។

សរុបមកដើម្បីដាំដុះចេកពងមាន់បានល្អ យើងគួរកត់សំគាល់នូវចំនុចសំខាន់ៗ មួយចំនួនដូចខាងក្រោម :

- ជីករណ្តៅទំហំ ៤ តឹកបួនជ្រុង ជំរៅ ២ តឹក និងដាក់ជីលាមកសត្វ ១ បង្គី នៅបាតរណ្តៅច្របល់លាយជាមួយដី

- ត្រៀមគល់ចេក និងកូនចេកសំរាប់ដាំ។ គល់ចេកពុះជា ២ ដោយក្នុងមួយរណ្តៅ ដាក់គល់ ១ ចំហៀង ដាក់ដាំដោយផ្ងារ គល់ឡើងលើ

- គ្របសំរាម និងស្លឹកឈើនៅគល់ចេកជាប្រចាំ នៅពេលសំរាម និងស្លឹកឈើចាប់ផ្តើមរលួយ ជ្រុំកប់ចូលក្នុងដី ហើយគ្របមួយសារទៀត

- ស្រោចទឹករយៈពេល ៣ ថ្ងៃម្តង ពេលកូនចេកនៅតូច (រដូវប្រាំង)



ទិដ្ឋភាពចំការចេកនៅពេលចេកធ្លាក់ស្ទង

- ដាក់ជីលាមកសត្វបន្ថែម ព្រមទាំងជ្រុំកប់នូវកំទេចសំរាម ចូលក្នុងដី ដើម្បីបង្កើនជីជាតិដី ជីលាមកសត្វដែលប្រើ ត្រូវជាជីដែលពុកផុយ

- បាចទឹកចេញ នៅពេលដែលមានភ្លៀងច្រើន ទឹកដក់នៅក្នុងចំការ

- ទុកតែ ២ ដើម ក្នុង ១ គុម្ព ដើម្បីអោយផ្លែលូតលាស់ធំល្អ។



សួនចំណាំ



របៀបផលិតជីកំប៉ុស្តគោក និង ទឹក